COUNCIL OF EUROPE CONSEIL DE L'EUROPE

សេរីសន្ធិសញ្ញាអឺរ៉ុប លេខ ១៨៥

# អនុសញ្ញា
# ស្តីពីឧក្រិដ្ឋកម្មតាមបណ្តាញ
# ព័ត៌មានវិទ្យា

ប៊ូដាប៉េស្ត ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០១

# បុព្វកថា

រដ្ឋសមាជិកនៃក្រុមប្រឹក្សាអឺរ៉ុប និងរដ្ឋហត្ថលេខីផ្សេងទៀត

ដោយគិតថាបំណងរបស់ក្រុមប្រឹក្សាអឺរ៉ុបគឺបង្កើតឱ្យមានសាមគ្គីភាពកាន់តែស្អិតល្មួតរវាងរដ្ឋសមាជិករបស់ខ្លួន

ដោយទទួលស្គាល់អំពីសារប្រយោជន៍នៃការពង្រីកកិច្ចសហប្រតិបត្តិការជាមួយរដ្ឋភាគីផ្សេងទៀតនៃអនុសញ្ញានេះ

ដោយជឿជាក់លើភាពចាំបាច់ក្នុងការរៀបចំជាអាទិភាពនូវគោលនយោបាយព្រហ្មទណ្ឌរួមមួយសំដៅការពារសង្គមប្រឆាំងនឹងឧក្រិដ្ឋកម្មតាមបណ្តាញអាំងទែរណែត ជាពិសេសតាមរយៈការអនុម័តបទប្បញ្ញត្តិសមស្របមួយ និងតាមរយៈការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ

ដោយដឹងច្បាស់អំពីបម្រែបម្រួលយ៉ាងខ្លាំងកើតចេញពីការប្រើបច្ចេកវិទ្យាអេឡិចត្រូនិក ការប្រមូលផ្តុំគ្នា និងសកលភាវូបនីយកម្មបណ្តាញព័ត៌មានវិទ្យា

ដោយខ្វាយខ្វល់អំពីគ្រោះភ័យចំពោះការដែលបណ្តាញព័ត៌មានវិទ្យា និងព័ត៌មានតាមបណ្តាញអេឡិចត្រូនិក ត្រូវគេយកទៅប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ និងអំពីគ្រោះភ័យបង្កឡើងដោយសារតែភស្តុតាងបទល្មើសទាំងនោះត្រូវស្តុក និងបញ្ជូនតាមបណ្តាញព័ត៌មានវិទ្យា

ដោយទទួលស្គាល់អំពីភាពចាំបាច់នៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋ និងវិស័យឯកជនក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មតាមបណ្តាញព័ត៌មានវិទ្យា និងទទួលស្គាល់ភាពចាំបាច់នៃកិច្ចការពារផលប្រយោជន៍ស្របច្បាប់ក្នុងការប្រើប្រាស់ និងអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មានវិទ្យា

ដោយវាយតម្លៃថាការងារប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មតាមបណ្តាញអាំងទែរណែតអាចប្រព្រឹត្តិទៅបានល្អលុះត្រាតែមានកិច្ចសហការអន្តរជាតិក្នុងផ្នែកព្រហ្មទណ្ឌឱ្យបានកាន់ច្រើនឡើង រហ័ស និងប្រកបដោយប្រសិទ្ធភាព

ដោយជឿជាក់ថាអនុសញ្ញានេះចាំបាច់សម្រាប់បង្ការទប់ស្កាត់ទង្វើដែលប៉ះពាល់ដល់ភាពសម្ងាត់ បូរណភាព និងភាពនៅទំនេររបស់ប្រព័ន្ធព័ត៌មានវិទ្យា របស់បណ្តាញ និងទិន្នន័យ រួមទាំងការប្រើប្រាស់ដោយខុសច្បាប់នូវប្រព័ន្ធណាមួយ បណ្តាញណាមួយ និងទិន្នន័យណាមួយ ដែលធានាឱ្យមានការចោទប្រកាន់ចំពោះឥរិយាបថ ដូចអ្វីដែលបានពិពណ៌នាក្នុងអនុសញ្ញានេះ និងការសម្របសម្រួលសមត្ថកិច្ចដើម្បីអនុញ្ញាតឱ្យមានការប្រយុទ្ធប្រឆាំងប្រកបដោយប្រសិទ្ធភាពប្រឆាំងនឹងបទល្មើសព្រហ្មទណ្ឌ តាមរយៈការជួយសម្រួលក្នុងការស្វែងរកបទល្មើសទាំងនោះ ស៊ើបអង្កេត និងការចោទប្រកាន់ ទាំងនៅក្នុងប្រទេសនិងអន្តរជាតិ និងដោយមានទាំងចែងអំពីការដាក់ឱ្យប្រើប្រាស់នូវលិខិតូបករណ៍សម្រាប់ធ្វើកិច្ចសហប្រតិបត្តិការលក្ខណៈអន្តរជាតិដ៏ឆាប់រហ័ស និងអាចទុកចិត្តបាន

ដោយតែងតែចងចាំក្នុងចិត្តអំពីភាពចាំបាច់ក្នុងការធានាតុល្យភាពរវាងប្រយោជន៍នៃសកម្មភាពបង្ក្រាប និងធានាការគោរពសិទ្ធិមនុស្សជាមូលដ្ឋាន ដូចការធានាដែលមានចែងក្នុងអនុសញ្ញារួមស្តីអំពីកិច្ចការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៃក្រុមប្រឹក្សាអឺរ៉ុប (១៩៥០) ក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិល និងនយោបាយរបស់អង្គការសហប្រជាជាតិ (១៩៦៦) រួមទាំងនៅក្នុងអនុសញ្ញាអន្តរជាតិផ្សេងទៀតអនុវត្តក្នុងវិស័យសិទ្ធិមនុស្ស ដែលធានានូវសិទ្ធិក្នុងការបញ្ចេញមតិដោយគ្មានការភិតភ័យ សិទ្ធិក្នុងការបញ្ចេញមតិ បូករួមទាំងសិទ្ធិស្វែងរក ទទួលបាន និងផ្សព្វផ្សាយព័ត៌មាន គំនិតគ្រប់ប្រភេទ ដោយគ្មានព្រំដែន បូករួមទាំងសិទ្ធិក្នុងការគោរពជីវិតឯកជន

ដោយយល់ច្បាស់ផងដែរអំពីសិទ្ធិក្នុងការការពារទិន្នន័យផ្ទាល់ខ្លួន ដូចអ្វីដែលមានចែងជាពិសេសក្នុងអនុសញ្ញា ១៩៨១ របស់ក្រុមប្រឹក្សាអឺរ៉ុបសម្រាប់ការពារបុគ្គលប្រឆាំងនឹងប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនដោយមិនឱ្យសាមីជនដឹងខ្លួន

ដោយគិតគូរអំពីអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (១៩៨៩) និងសន្ធិសញ្ញាអង្គការពលកម្មអន្តរជាតិ (OIT) ស្តីពីទម្រង់ដ៏អាក្រក់នៃពលកម្មកុមារ (១៩៩៩)

ដោយយកចិត្តទុកដាក់អំពីអនុសញ្ញាមានស្រាប់របស់ក្រុមប្រឹក្សាអឺរ៉ុបស្តីពីសហប្រតិបត្តិការក្នុងវិស័យព្រហ្មទណ្ឌ រួមទាំងសន្ធិសញ្ញាស្រដៀងគ្នាផ្សេងៗទៀតចុះកិច្ចព្រមព្រៀងរវាងរដ្ឋសមាជិកក្រុមប្រឹក្សាអឺរ៉ុប និងរដ្ឋផ្សេងៗ ហើយដែលគួសបញ្ជាក់ថាអនុសញ្ញានេះមានគោលបំណងបំពេញបន្ថែមលើអនុសញ្ញា និងសន្ធិសញ្ញាមានស្រាប់ទាំងឡាយ ដើម្បីធ្វើឱ្យកាន់តែមានប្រសិទ្ធភាពសម្រាប់ការស៊ើបអង្កេត និងនីតិវិធីព្រហ្មទណ្ឌស្តីពីបទល្មើសព្រហ្មទណ្ឌពាក់ព័ន្ធនឹងប្រព័ន្ធព័ត៌មានវិទ្យា និងទិន្នន័យព័ត៌មានវិទ្យា រួមទាំងអនុញ្ញាតឱ្យមានការប្រមូលភស្តុតាងអេឡិចត្រូនិកនៃបទល្មើសព្រហ្មទណ្ឌ

ដោយគាំទ្រចំពោះគំនិតផ្តួចផ្តើមកន្លងទៅថ្មីៗសំដៅលើកកម្ពស់ការយល់ដឹង និងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងទិសដៅប្រយុទ្ធប្រឆាំងនឹងបទឧក្រិដ្ឋកម្មតាមបណ្តាញអាំងទែរណែត ជាពិសេសសកម្មភាពដឹកនាំដោយអង្គការសហប្រជាជាតិ អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OCDE) សហភាពអឺរ៉ុប និងប្រទេសមហាអំណាចសេដ្ឋកិច្ចទាំង៨ ( G8)

ដោយតែងតែនឹកឃើញអំពីអនុសាសន៍របស់គណៈកម្មាធិការរដ្ឋមន្ត្រីអឺរ៉ុប លេខ R ( 85) 10 ទាក់ទិននឹងការអនុវត្តអនុសញ្ញាអឺរ៉ុបស្តីពីកិច្ចសហប្រតិបត្តិការផ្នែកគតិយុត្តិផ្នែកព្រហ្មទណ្ឌទាក់ទិននឹងគណៈកម្មការសម្រេចសម្រាប់ការឃ្លាំមើលផ្នែកទូរគមនាគមន៍ លេខ R (៨៨) 2 ស្តីពីវិធានការសម្រាប់ប្រយុទ្ធប្រឆាំងនឹងការលួចបន្លំក្នុងវិស័យសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនេះ លេខ R (87) 15 សំដៅកំណត់បទបញ្ជាលើការប្រើប្រាស់ទិន្នន័យលក្ខណៈផ្ទាល់ខ្លួនក្នុងវិស័យនគរបាល លេខ R (95) 4 ស្តីពីការការពារទិន្នន័យផ្ទាល់ខ្លួនក្នុងសេវាកម្មទូរគមនាគមន៍ ជាពិសេសទាក់ទិននឹងសេវាកម្មទូរស័ព្ទ និងលេខ R (89) 9 ស្តីពីឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងកុំព្យូទ័រ ដែលបញ្ជាក់ប្រាប់ដល់អ្នកច្បាប់ជាតិនូវគោលការណ៍មេសម្រាប់កំណត់និយមន័យនៃបទល្មើសព័ត៌មានវិទ្យា រួមទាំងលេខ R (95) 13 ទាក់ទិននឹងផ្នែកនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន

ដោយគិតដល់សេចក្តីសម្រេច លេខ 1 អនុម័តដោយគណៈកម្មាធិការរដ្ឋមន្ត្រីយុត្តិធម៌អឺរ៉ុបក្នុងឱកាសសន្និបាតលើកទី២១ (ទីក្រុងប្រាក ថ្ងៃទី១០ និង ១១ មិថុនា ១៩៩៧) ដែលផ្តល់អនុសាសន៍ឱ្យ

គណៈកម្មាធិការរដ្ឋមន្ត្រីអឺរ៉ុបគាំទ្រសកម្មភាពប្រឆាំងនឹងឧក្រិដ្ឋកម្មតាមបណ្ដាញព័ត៌មានវិទ្យាដឹកនាំដោយគណៈកម្មាធិការអឺរ៉ុប សម្រាប់ផ្នែកឧក្រិដ្ឋកម្ម (CDPC) ដើម្បីបង្ខិតឱ្យជិតគ្នារវាងបទប្បញ្ញត្តិថ្នាក់ជាតិស្ដីពីព្រហ្មទណ្ឌ និងអនុញ្ញាតឱ្យមានការប្រើប្រាស់មធ្យោបាយស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពទាក់ទិននឹងបទល្មើសព័ត៌មាន ហើយដោយគិតគូរដល់សេចក្ដីសម្រេច លេខ 3 អនុម័តក្នុងឱកាសសន្និបាតរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អឺរ៉ុបលើកទី២៣ (ទីក្រុងឡុង ៨ និង៩ មិថុនា ២០០០) ដែលលើកទឹកចិត្តឱ្យភាគីទាំងអស់ចរចាគ្នាដើម្បីបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការស្វែងរកដំណោះស្រាយដែលអាចឱ្យរដ្ឋមួយចំនួនធំក្លាយជាសមាជិកអនុសញ្ញានេះ និងទទួលស្គាល់ថាចាំបាច់គេត្រូវមានយន្តកម្មរហ័ស និងប្រកបដោយប្រសិទ្ធភាពសម្រាប់ធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិ ដោយគិតគូរជាពិសេសដល់តម្រូវការពិសេសក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មតាមបណ្ដាញព័ត៌មានវិទ្យា

ដោយគិតគូរអំពីផែនការសកម្មភាពដែលអនុម័តដោយប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលនៃក្រុមប្រឹក្សាអឺរ៉ុបក្នុងឱកាសកិច្ចប្រជុំកំពូលលើកទី២ (ស្ត្រាស្បួរ ថ្ងៃទី១០ និង១១ តុលា ១៩៩៧) ដើម្បីស្វែងរកចម្លើយរួមគ្នាមួយតបទៅនឹងការវិវត្តនៃបច្ចេកវិទ្យាថ្មីៗផ្នែកព័ត៌មាន ដោយផ្អែកលើបទដ្ឋាន និងស្មារតីរបស់ក្រុមប្រឹក្សាអឺរ៉ុប

បានព្រមព្រៀងគ្នាដូចខាងក្រោម៖

# ជំពូក១ - វាក្យសព្ទ

សម្រាប់អនុសញ្ញានេះ

ក ពាក្យថា «ប្រព័ន្ធព័ត៌មានវិទ្យា» សំដៅលើឧបករណ៍មួយដាច់ពីគេ ឬកន្សោមឧបករណ៍តភ្ជាប់គ្នាជាបណ្ដាញ ឬភ្ជាប់ទៅនឹងបណ្ដាញមេមួយ ដែលរ៉ាប់រង ឬដែលធាតុផ្សំរបស់វាជាច្រើនរ៉ាប់រងការប្រើប្រាស់ឯកសារដោយស្វ័យប្រវត្តិ តាមរយៈកម្មវិធីមួយ។

ខ ពាក្យថា «ទិន្នន័យព័ត៌មានវិទ្យា» សំដៅលើរាល់ការបង្ហាញហេតុការណ៍ ព័ត៌មាន ឬទ្រឹស្ដីក្រោមទម្រង់មួយត្រៀមសម្រាប់បើកប្រើប្រាស់ជាលក្ខណៈព័ត៌មានវិទ្យា បូករួមទាំងប្រភេទកម្មវិធីសម្រាប់ឱ្យប្រព័ន្ធព័ត៌មានវិទ្យាមួយបំពេញមុខងារណាមួយ

គ ពាក្យថា «អ្នកផ្គត់ផ្គង់សេវាកម្ម» សំដៅលើ៖

i រាល់អង្គភាពសាធារណៈ ឬឯកជន ដែលអនុញ្ញាតឱ្យអតិថិជនរបស់ខ្លួនទាក់ទងគ្នាតាមរយៈប្រព័ន្ធព័ត៌មានវិទ្យាមួយ និង

ii រាល់អង្គភាពផ្សេងទៀតដែលប្រើប្រាស់ ឬស្ដុកទិន្នន័យព័ត៌មានវិទ្យាសម្រាប់សេវាកម្មទំនាក់ទំនងនេះ ឬសម្រាប់អ្នកប្រើប្រាស់របស់ខ្លួន

ឃ «ទិន្នន័យអំពីចរាចរណ៍» សំដៅលើរាល់ទិន្នន័យដែលមានលក្ខណៈជាទំនាក់ទំនងឆ្លងកាត់តាមប្រព័ន្ធព័ត៌មានវិទ្យា ដែលប្រព័ន្ធនេះផលិតឡើងក្នុងនាមជាធាតុមួយនៃខ្សែបណ្ដាញទំនាក់ទំនងដោយមានបញ្ជាក់អំពីប្រភព, ទិសដៅ, ផ្លូវ, ម៉ោង, កាលបរិច្ឆេទ, ទំហំទិន្នន័យ, និងរយៈពេលទំនាក់ទំនង ឬប្រភេទសេវាកម្មរួមផ្សំជាមួយ ។

# ជំពូក ២ - វិធានការត្រូវអនុវត្តនៅថ្នាក់ជាតិ

## ផ្នែកទី១ - នីតិព្រហ្មទណ្ឌទាក់ទិននឹងសម្ភារ

### ចំណងជើង ១ - បទល្មើសប្រឆាំងនឹងភាពសម្ងាត់ បូរណភាព និងភាពទំនេរនៃទិន្នន័យ និងប្រព័ន្ធព័ត៌មានវិទ្យា

#### មាត្រា ២ - ការប្រើប្រាស់ដោយខុសច្បាប់

ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតថាចាំបាច់ដើម្បីចាត់ចូលជាបទល្មើសព្រហ្មទណ្ឌអនុលោមទៅតាមច្បាប់ក្នុងស្រុករបស់ខ្លួន នូវការប្រើប្រាស់ដោយចេតនា និងដោយពុំមានសិទ្ធិនូវប្រព័ន្ធព័ត៌មានវិទ្យាមួយទាំងមូល ឬមួយផ្នែក។ ភាគីមួយអាចទាមទារបានថាបទល្មើសនោះប្រព្រឹត្តឡើងបំពានលើវិធានការសន្តិសុខ ក្នុងគោលបំណងទទួលបានទិន្នន័យព័ត៌មាន

វិទ្យា ឬក្នុងគោលបំណងល្មើសច្បាប់ផ្សេងទៀត ឬថាបទល្មើសនោះមានពាក់ព័ន្ធនឹងប្រព័ន្ធព័ត៌មានវិទ្យា ដែលតភ្ជាប់ទៅប្រព័ន្ធព័ត៌មានវិទ្យាមួយផ្សេងទៀត។

## មាត្រា៣ - ការចាប់យកព័ត៌មានដោយខុសច្បាប់

ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងផ្សេងៗទៀត ដែលខ្លួនយល់ថាចាំបាច់ដើម្បីចាត់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌស្របទៅតាមច្បាប់ក្នុងស្រុកខ្លួន ការចាប់យកដោយចេតនា និងដោយពុំមានសិទ្ធិ ដោយប្រើមធ្យោបាយបច្ចេកទេស នូវទិន្នន័យព័ត៌មានវិទ្យាក្នុងពេលគេផ្ញើចេញមិនសាធារណៈ ទៅកាន់ទិសដៅ ដោយមានប្រភពមកពីក្រៅ ឬនៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាមួយ បូករួមទាំងការផ្សព្វផ្សាយលក្ខណៈអេឡិចត្រូម៉ាញេទិកចេញពីប្រព័ន្ធព័ត៌មានវិទ្យាមួយ ដែលដឹកជញ្ជូនទិន្នន័យព័ត៌មានវិទ្យានោះ។ ភាគីមួយអាចទាមទារបានថាបទល្មើសមួយត្រូវបានប្រព្រឹត្តក្នុងចេតនាផ្ទុយនឹងច្បាប់ ឬមានជាប់ពាក់ព័ន្ធនឹងប្រព័ន្ធព័ត៌មានវិទ្យាដែលតភ្ជាប់ទៅបណ្ដាញព័ត៌មានមួយទៀត។

## មាត្រា៤ - ការប៉ះពាល់បូរណភាពនៃទិន្នន័យ

១ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតថាចាំបាច់ដើម្បីចាត់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួន នូវអំពើដោយចេតនា ឬដោយពុំមានសិទ្ធិ ដែលធ្វើឱ្យខូច លុប ឬធ្វើឱ្យខូចសភាពដើម កែ ឬរំលាយចោលនូវទិន្នន័យព័ត៌មានវិទ្យា។

២ ភាគីមួយអាចរក្សាសិទ្ធិក្នុងការទាមទារថបានថាឥរិយាបថដែលពណ៌នាក្នុងកថាខណ្ឌ ១ បង្កជាការខូចខាតធ្ងន់ធ្ងរ។

## មាត្រាទី ៥ - ការប៉ះពាល់ដល់បូរណភាពនៃប្រព័ន្ធ

ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដើម្បីចាត់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌអនុលោមទៅតាមច្បាប់ក្នុងស្រុករបស់ខ្លួន នូវការរំខានធ្ងន់ធ្ងរ ដោយចេតនា ឬដោយពុំមានសិទ្ធិ ចំពោះដំណើរការប្រព័ន្ធព័ត៌មានវិទ្យាមួយ តាមរយៈការជ្រៀតចូល ផ្សព្វផ្សាយ ធ្វើឱ្យខូច លុប ធ្វើឱ្យខូចសភាពដើម ឬរំលាយចោលទិន្នន័យព័ត៌មានវិទ្យា។

## មាត្រា៦ - ការបំពានលើឧបករណ៍

១ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនយល់ថាចាំបាច់ ដើម្បីចាត់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌស្របទៅតាមច្បាប់ក្នុងស្រុករបស់ខ្លួន នូវបទល្មើសផ្សេងៗដូចខាងក្រោម ត្រូវបានប្រព្រឹត្តដោយចេតនា ឬដោយគ្មានសិទ្ធិ រួមមាន៖

ក ការផលិត លក់ ទទួលបានមកប្រើ នាំចូល ចែកចាយ និងរូបភាពផ្សេងៗទៀតនៃការដាក់ឱ្យប្រើប្រាស់នូវ ៖

i ឧបករណ៍មួយ បូករួមទាំងកម្មវិធីព័ត៌មានវិទ្យា ដែលបង្កើតឡើង ឬកែសម្រួលដើម្បីឈានទៅប្រព្រឹត្តិបទល្មើសមួយក្នុងចំណោមបទល្មើសផ្សេងៗកំណត់ឡើងស្របទៅតាមមាត្រា ២ និងទី ៥ ខាងលើ

ii ពាក្យសម្ងាត់មួយ ឬលេខកូដសម្រាប់បើក ឬលេខកូដទិន្នន័យព័ត៌មានវិទ្យាប្រហាក់ប្រហែលនេះដែលអនុញ្ញាតឱ្យចូលប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាណាមួយទាំងស្រុង ឬមួយចំណែក

នៅក្នុងចេតនាប្រើដើម្បីប្រព្រឹត្តិបទល្មើសណាមួយក្នុងចំណោមបទល្មើសចែងនៅក្នុងមាត្រា២ និងទី៥ និង

ខ ការយកមកធ្វើជាកម្មសិទ្ធិនូវធាតុណាមួយ ដូចបានចែងក្នុងកថាខណ្ឌ ក.១ ខាងលើ ក្នុងចេតនាប្រើដើម្បីប្រព្រឹត្តិបទល្មើសណាមួយក្នុងចំណោមបទល្មើសចែងក្នុងមាត្រា២ និងទី៥។ ភាគីមួយអាចទាមទារសុំឱ្យធាតុណាមួយចំនួនក្នុងចំណោមធាតុទាំងនោះត្រូវបានរក្សាទុក ដើម្បីឱ្យអ្នកទទួលខុសត្រូវបទល្មើសចូលខ្លួនមកដោះស្រាយ

២ មាត្រានេះនឹងមិនបកស្រាយថាជាបទល្មើសព្រហ្មទណ្ឌឡើយ ខណៈដែលការផលិត ការលក់ ការទទួលយកមកប្រើប្រាស់ ការនាំចូល ការចែកចាយ និងទម្រង់ផ្សេងទៀតនៃការដាក់ឱ្យប្រើប្រាស់ដែលមានចែងនៅក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ពុំមានគោលបំណងប្រព្រឹត្តិបទល្មើសដូចដែលបានចែងស្របតាមមាត្រា២ ដល់ទី៥ នៃអនុសញ្ញានេះ ដូចក្នុងករណីសាកមានការអនុញ្ញាត ឬកិច្ចការការពារប្រព័ន្ធព័ត៌មានវិទ្យាមួយ។

៣ ភាគីនីមួយៗរក្សាសិទ្ធិក្នុងការមិនអនុវត្តកថាខណ្ឌទី១ នៃមាត្រានេះ ល្គឹកណាការរក្សាសិទ្ធិនោះមិនពាក់ព័ន្ធនឹងការលក់ ចែកចាយ ឬការដាក់ឱ្យប្រើប្រាស់នូវធាតុផ្សេងៗដែលមានចែងក្នុងកថាខណ្ឌ ១.ក.២ នៃមាត្រានេះ។

## ចំណងជើង ២ - បទល្មើសព័ត៌មានវិទ្យា

### មាត្រា៧ - ការក្លែងបន្លំព័ត៌មានវិទ្យា

ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗ ដែលខ្លួនគិតថាចាំបាច់ ដើម្បីចាត់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួន នូវការជ្រៀតចូល ការធ្វើឱ្យខូចសភាពដើម ការលុប ឬការរំលាយចោល ដោយចេតនា ឬដោយពុំមានសិទ្ធិនូវទិន្នន័យព័ត៌មានវិទ្យា ដែលបង្កឱ្យទិន្នន័យនោះបាត់លក្ខណៈដើម ក្នុងចេតនាយកមកកាន់កាប់ ឬប្រើក្នុងបំណងស្របច្បាប់ហាក់ដូចជាទិន្នន័យទាំងនោះជាទិន្នន័យដើម ដែលគេអាចស្គាល់បាន ឬយល់បានដោយផ្ទាល់ ឬមិនផ្ទាល់។ ភាគីមួយអាចអាចទាមទាររកចេតនាបន្លំ ឬចេតនាល្មើសច្បាប់ ដើម្បីឱ្យអ្នកទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌចូលខ្លួនមកដោះស្រាយ។

### មាត្រាទី៨ - ការលួចបន្លំព័ត៌មានវិទ្យា

ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ ឬវិធានការផ្សេងៗទៀត ដែលខ្លួនគិតឃើញថាចាំបាច់ ដើម្បីចាត់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួន នូវទង្វើចេតនា និងដោយពុំមានសិទ្ធិ ដែលបង្កព្យសនកម្មលើទ្រព្យសម្បត្តិរបស់អ្នកដទៃ

ក តាមរយៈការជ្រៀតចូល ការធ្វើឱ្យខូចសភាពដើម ការលុប ឬការរំលាយចោល នូវទិន្នន័យព័ត៌មានវិទ្យា

ខ រាល់ការប៉ះពាល់ចំពោះដំណើរការប្រព័ន្ធព័ត៌មានវិទ្យាមួយ

ក្នុងចេតនាលួចបន្លំ ឬប្រព្រឹត្តល្មើស ដើម្បីទទួលទាំងខ្លួនពុំមានសិទ្ធិនូវផលប្រយោជន៍សេដ្ឋកិច្ចសម្រាប់ខ្លួនឯងផ្ទាល់ ឬសម្រាប់អ្នកដទៃ។

## ចំណងជើង ៣ - បទល្មើសពាក់ព័ន្ធនឹងខ្លឹមសារ

### មាត្រា៩ - បទល្មើសពាក់ព័ន្ធនឹងរូបភាពអាសអាភាសកុមារ

១ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងនីតិវិធីផ្សេងៗទៀត ដែលខ្លួនគិតឃើញថាចាំបាច់ ដើម្បីចាត់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួន នូវទង្វើដែលប្រព្រឹត្តឡើងដោយចេតនា ឬដោយពុំមានសិទ្ធិដូចខាងក្រោម៖

ក ការផលិតរូបភាពអាសអាភាសកុមារសម្រាប់យកទៅផ្សព្វផ្សាយលើប្រព័ន្ធព័ត៌មានវិទ្យាមួយ

ខ ការផ្តត់ផ្គង់ ឬដាក់ឱ្យប្រើប្រាស់រូបភាពអាសអាភាសកុមារតាមរយៈប្រព័ន្ធព័ត៌មានវិទ្យាមួយ

គ ការផ្សព្វផ្សាយ ឬបញ្ជូនរូបភាពអាសអាភាសកុមារតាមរយៈប្រព័ន្ធព័ត៌មានវិទ្យាមួយ

ឃ ការទាញយក ឬផ្តល់ទៅឱ្យអ្នកដទៃនូវរូបភាពអាសអាភាសកុមារតាមប្រព័ន្ធព័ត៌មានវិទ្យា

ង ការកាន់កាប់រូបភាពអាសអាភាសកុមារនៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា ឬក្នុងឧបករណ៍ស្តុកទិន្នន័យព័ត៌មានវិទ្យាមួយ

២ យោងតាមគោលដៅនៃកថាខណ្ឌទី១ខាងលើ ពាក្យថា «រូបភាពអាសអាភាសកុមារ» រួមមានរូបភាពគ្រប់ប្រភេទដែលអាចមើលឃើញនឹងភ្នែកបាន រួមមានៈ

ក អនីតិជនដែលយករូបរាងទៅសម្តែងចេញនូវឥរិយាបថទាក់ទាញអារម្មណ៍ផ្លូវភេទ

ខ បុគ្គលម្នាក់ដែលបញ្ចេញកាយវិការប្រៀបបាននឹងអនីតិជនដែលបញ្ចេញឥរិយាបថលក្ខណៈទាក់ទាញអារម្មណ៍ផ្លូវភេទ

គ រូបភាពជាក់ស្តែងដែលបង្ហាញអនីតិជនម្នាក់បញ្ចេញឥរិយាបថលក្ខណៈទាក់ទាញអារម្មណ៍ផ្លូវភេទ។

៣ តាមគោលបំណងរបស់កថាខណ្ឌទី២ខាងលើ ពាក្យថា «អនីតិជន» សំដៅលើរាល់បុគ្គលដែលមានអាយុក្រោម ១៨ ឆ្នាំ។ ក៏ប៉ុន្តែ ភាគីមួយអាចទាមទារបានសម្រាប់ការកំណត់អាយុក្រោមនេះ ដូចជាអាចគិតចាប់ពីក្រោម ១៦ ឆ្នាំ។

៤ ភាគីមួយអាចរក្សាសិទ្ធិក្នុងការមិនអនុវត្តទាំងស្រុងឬមួយផ្នែកទៅតាមកថាខណ្ឌទី១ ពីវាក្យខណ្ឌ ឃ. ដល់វាក្យខណ្ឌ ង. និងកថាខណ្ឌទី២ ពីវាក្យខណ្ឌ ខ. ដល់ គ.។

## ចំណងជើងទី៤ - បទល្មើសទាក់ទិននឹងការប៉ះពាល់លើកម្មសិទ្ធិបញ្ញា និងច្បាប់ជាប់ពាក់ព័ន្ធ

### មាត្រា១០ - បទល្មើសទាក់ទិននឹងការប៉ះពាល់លើកម្មសិទ្ធិបញ្ញា និងច្បាប់ជាប់ពាក់ព័ន្ធ

១ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលគិតឃើញថាចាំបាច់ ដើម្បីចាត់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួន នូវការប៉ះពាល់ទៅលើកម្មសិទ្ធិបញ្ញាកំណត់ឡើងដោយនីតិប្បញ្ញត្តិរបស់ភាគី ស្របនឹងកាតព្វកិច្ចដែលភាគីនោះបានទទួល ដោយអនុវត្តតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីសចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៧១ ស្តីពីការពិនិត្យឡើងវិញលើអនុសញ្ញាទីក្រុងប៊ឺន (Berne) ស្តីពីការពារស្នាដៃអក្សរសិល្ប៍ និងស្នាដៃសិល្បៈ, កិច្ចព្រមព្រៀងស្តីពីក្របខណ្ឌពាណិជ្ជកម្មនៃច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា និងសន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (OMPI) ស្តីពីកម្មសិទ្ធិបញ្ញាលើកលែងតែសិទ្ធិសីលធម៌ ចែងដោយអនុសញ្ញាទាំងនោះ នៅពេលដែលអំពើល្មើសណាមួយត្រូវប្រព្រឹត្តឡើងដោយចេតនា ទាក់ទិននឹងការធ្វើអាជីវកម្ម ដោយប្រើប្រព័ន្ធព័ត៌មានវិទ្យា។

២ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលគិតឃើញថាចាំបាច់ ដើម្បីចាត់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួន នូវការប៉ះពាល់ទៅលើច្បាប់ពាក់ព័ន្ធកំណត់នៅក្នុងនីតិប្បញ្ញត្តិរបស់ភាគី ស្របនឹងតាមកាតព្វកិច្ចដែលភាគីបានយល់ព្រមទទួល ដោយអនុវត្ត

តាមអនុសញ្ញាអន្តរជាតិសម្រាប់ការពារសិល្បករសម្តែង ឬសិល្បករអនុវត្តការងារ ផលិតករកម្មវិធី និងអង្គភាពផ្សព្វផ្សាយតាមរលកធាតុអាកាស (អនុសញ្ញាក្រុងរ៉ូម), ដោយអនុវត្តតាមកិច្ចព្រមព្រៀងទាក់ទិននឹងក្របខណ្ឌពាណិជ្ជកម្មនៃច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា និងសន្ធិសញ្ញា OMPI ស្តីពីការសម្តែង ការអនុវត្តការងារ និងការបញ្ចូលសំឡេង លើកលែងតែសិទ្ធិខាងសីលធម៌ ដែលចែងក្នុងអនុសញ្ញាទាំងនោះ នៅពេលដែលអំពើល្មើសត្រូវប្រព្រឹត្តឡើងដោយចេតនា ក្នុងគោលបំណងធ្វើអាជីវកម្ម ដោយប្រើប្រព័ន្ធព័ត៌មានវិទ្យា។

៣ ក្នុងកាលៈទេសៈពិសេសនិងជាក់លាក់បំផុត ភាគីមួយអាចរក្សាសិទ្ធិមិនទទួលយកទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២ នៃមាត្រានេះ ក្នុងលក្ខខណ្ឌដែលគេអាចពឹងពាក់លើច្បាប់ផ្សេងទៀតបាន និងក្នុងលក្ខខណ្ឌដែលការរក្សាសិទ្ធិនេះមិនប៉ះពាល់ដល់កាតព្វកិច្ចអន្តរជាតិដែលគេតម្រូវសម្រាប់ភាគីនោះ ដោយអនុវត្តទៅតាមឧបករណ៍ច្បាប់អន្តរជាតិដែលមានលើកឡើងក្នុងកថាខណ្ឌទី១ និងទី២ នៃមាត្រានេះ។

## ចំណងជើងទី៥ - ទម្រង់ផ្សេងទៀតនៃទំនួលខុសត្រូវ និងការដាក់ទោស

### មាត្រា១១ - ការប៉ុនប៉ង និងផ្សំគំនិត

១ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលគិត ឃើញថាចាំបាច់ ដើម្បីចាត់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួន នូវរាល់អំពើផ្សំគំនិត ប្រព្រឹត្តឡើងដោយចេតនា ក្នុងគោលដៅរៀបចំប្រព្រឹត្តបទល្មើសមួយក្នុងចំណោមបទល្មើសផ្សេងៗ ដូចបានកំណត់ឡើងទៅតាមមាត្រា២ និងទី១០ នៃអនុសញ្ញានេះ។

២ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលគិតឃើញថាចាំបាច់ ដើម្បីចាត់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួន នូវរាល់ការប៉ុនប៉ងក្នុងចេតនាប្រព្រឹត្តបទល្មើសមួយក្នុងចំណោមបទល្មើសផ្សេងៗ ដែលកំណត់ឡើងទៅតាមពីមាត្រា៣ ដល់ទី៥, ៧, ៨, ៩.១.ក និងគ នៃអនុសញ្ញានេះ។

៣ ភាគីនីមួយអាចរក្សាសិទ្ធិមិនអនុវត្តកថាខណ្ឌទី២ នៃមាត្រានេះទាំងស្រុង ឬមួយផ្នែក។

### មាត្រាទី១២ - ទំនួលខុសត្រូវរបស់នីតិបុគ្គល

១ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងទៀតដែលខ្លួនយល់ថាចាំបាច់ ដើម្បីឱ្យនីតិបុគ្គលអាចចេញមុខទទួលខុសត្រូវចំពោះបទល្មើសដែលចែងឡើងដោយអនុវត្តទៅតាមអនុសញ្ញានេះ នៅពេលដែលវាត្រូវបានប្រព្រឹត្តឡើងដោយរាល់រូបវន្តបុគ្គលដើម្បីបម្រើផលប្រយោជន៍ខ្លួន ហើយដែលសកម្មភាពនោះធ្វើឡើងម្នាក់ឯងក្នុងនាមជាសមាជិកនៃផ្នែកមួយរបស់នីតិបុគ្គល ដែលកាន់កាប់សិទ្ធិអំណាចដឹកនាំក្នុងអង្គភាពនោះ ដោយសម្អាងលើ៖

ក សិទ្ធិអំណាចជាអ្នកតំណាងរបស់នីតិបុគ្គល

ខ សិទ្ធិអំណាចក្នុងការសម្រេចជំនួសនីតិបុគ្គល

គ សិទ្ធិអំណាចដើម្បីបំពេញការងារត្រួតពិនិត្យនៅក្នុងនីតិបុគ្គលនោះ។

២ ក្រៅពីករណីដូចបានចែងនៅកថាខណ្ឌទី១ នៃមាត្រានេះ ភាគីនីមួយៗអនុម័តវិធានការដែលខ្លួនគិតឃើញថាចាំបាច់ ដើម្បីធានាថានីតិបុគ្គលមួយរូបអាចចេញមុខទទួលខុសត្រូវ ខណៈពេលអវត្តមាននៃការឃ្លាំមើល និងការត្រួតពិនិត្យពីសំណាក់រូបវន្តបុគ្គលដូចមានចែងក្នុងកថាខណ្ឌទី១ បានបង្កឱ្យការប្រព្រឹត្តបទល្មើសដែលបានចែងទៅតាមអនុសញ្ញានេះសម្រាប់ជាប្រយោជន៍របស់នីតិបុគ្គលអាចប្រព្រឹត្តទៅបានដោយរូបវន្តបុគ្គលដែលធ្វើសកម្មភាពក្រោមអំណាចរបស់ខ្លួន។

៣ តាមគោលការណ៍គតិយុត្តិរបស់ភាគី ទំនួលខុសត្រូវរបស់នីតិបុគ្គលអាចជាទំនួលខុសត្រូវលក្ខណៈព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬរដ្ឋបាល។

៤ ទំនួលខុសត្រូវនេះត្រូវបានកំណត់ឡើងដោយមិនពាក់ព័ន្ធនឹងទំនួលខុសត្រូវលក្ខណៈព្រហ្មទណ្ឌនៃរូបវន្តបុគ្គលដែលបានប្រព្រឹត្តបទល្មើស។

### មាត្រា១៣ - ទោស និងវិធានការ

១ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗ ដែលខ្លួនគិតឃើញថាចាំបាច់ដើម្បីឱ្យបទល្មើសព្រហ្មទណ្ឌដែលកំណត់ឡើងស្របតាមមាត្រាពីទី២ ដល់ទី១១ ឈានទៅទទួលទោសជាក់ស្តែង សមស្រប និងធ្វើឱ្យរាងចាល បូករួមទាំងទោសបំបិទសិទ្ធិសេរីភាព។

២ ភាគីនីមួយៗត្រូវធ្វើយ៉ាងណាឱ្យនីតិបុគ្គលដែលចូលខ្លួនមកទទួលខុសត្រូវស្របតាមមាត្រា១២ ឈានទៅទទួលទោស ឬវិធានការលក្ខណៈព្រហ្មទណ្ឌជាក់ស្តែង សមស្រប និងធ្វើឱ្យរាងចាល បូករួមទាំងទោសបង់ពិន័យជាសាច់ប្រាក់។

# ផ្នែក២ - ច្បាប់ស្តីពីនីតិវិធី

## ចំណងជើងទី១ - បញ្ញត្តិរួម

### មាត្រា១៤ - ដែនកំណត់នៃការអនុវត្តវិធានការ និងច្បាប់នីតិវិធី

១ ភាគីនីមួយៗអនុម័តវិធានការ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតឃើញថាចាំបាច់ដើម្បីបង្កើតសិទ្ធិអំណាច និងនីតិវិធីដូចមានចែងក្នុងផ្នែកនេះក្នុងគោលដៅស៊ើបអង្កេត ឬចេញនីតិវិធីព្រហ្មទណ្ឌពិសេស។

២ លើកលែងតែបញ្ញត្តិផ្ទុយពីនេះដែលមានចែងក្នុងមាត្រា២១ ពុំនោះទេភាគីនីមួយៗត្រូវអនុវត្តសិទ្ធិអំណាច និងនីតិវិធីដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ៖

ក សម្រាប់បទល្មើសព្រហ្មទណ្ឌដែលចែងឡើងអនុលោមទៅតាមមាត្រា២ដល់១១នៃអនុសញ្ញានេះ

ខ សម្រាប់រាល់បទល្មើសព្រហ្មទណ្ឌដែលប្រព្រឹត្តឡើងដោយប្រើប្រព័ន្ធព័ត៌មានវិទ្យា និង

គ សម្រាប់ការប្រមូលភស្តុតាងអេឡិចត្រូនិកទាក់ទិននឹងរាល់បទល្មើសព្រហ្មទណ្ឌ។

៣ ក (ភាគីនីមួយៗអាចរក្សាសិទ្ធិអនុវត្តវិធានការចែងក្នុងមាត្រា២០ ត្រឹមតែសម្រាប់បទល្មើស ឬប្រភេទបទល្មើសពិសេសកំណត់នៅក្នុងការរក្សាសិទ្ធិ ដើម្បីកុំឱ្យកម្រិតនៃបទល្មើស និងប្រភេទបទល្មើស ត្រូវកាត់បន្ថយមកនៅស្រាលជាងកម្រិតបទល្មើសជាក់ស្តែង ដែលភាគីនោះអនុវត្តវិធានការដូចមានចែងនៅមាត្រា២១។) ភាគីនីមួយៗនឹងគ្រោងកំណត់ការរក្សាសិទ្ធិដើម្បីអាចអនុវត្តវិធានការចែងនៅមាត្រា២០ ឱ្យបានកាន់តែទូលំទូលាយតាមតែអាចធ្វើទៅបាន។

ខ ប្រសិនបើដោយសារការដាក់កំហិតពីច្បាប់ជាធរមានរបស់ខ្លួន នៅគ្រាធ្វើសច្ចាប័នលើអនុសញ្ញានេះ នៅពេលដែលភាគីមួយពុំអាចអនុវត្តវិធានការចែងនៅមាត្រា២០ និង២១ ទាក់ទិននឹងទិន្នន័យផ្សាយក្នុងប្រព័ន្ធព័ត៌មានវិទ្យាមួយរបស់អ្នកផ្គត់ផ្គង់សេវាកម្ម៖

i ដែលបង្កើតឡើងដើម្បីផលចំណេញរបស់អ្នកប្រើប្រាស់តែមួយក្រុមតូច និង

ii ដែលមិនប្រើប្រាស់បណ្តាញទូរគមនាគមន៍សាធារណៈ និងមិនតភ្ជាប់ទៅប្រព័ន្ធព័ត៌មានវិទ្យាមួយផ្សេងទៀត មិនថាសាធារណៈ ឬឯកជននោះទេ

ភាគីនោះអាចរក្សាសិទ្ធិមិនអនុវត្តវិធានការទាំងនេះចំពោះទំនាក់ទំនងបែបនោះ។ ភាគីនីមួយៗនឹងគ្រោងកំណត់ការរក្សាសិទ្ធិបែបនេះ ដើម្បីអាចអនុវត្តវិធានការចែងនៅក្នុងមាត្រទី២០ និង២១ ឱ្យបានទូលំទូលាយតាមតែអាចធ្វើទៅបាន។

## មាត្រា១៥ - លក្ខខណ្ឌ និងការការពារ

១ ភាគីនីមួយៗធ្វើយ៉ាងណាឱ្យការបង្កើត ដាក់ឱ្យដំណើរការ និងការអនុវត្តនូវសិទ្ធិអំណាច និងនីតិវិធីចែងក្នុងផ្នែកនេះ ស្ថិតក្រោមលក្ខខណ្ឌ និងកិច្ចការពារចែងដោយច្បាប់ក្នុងស្រុករបស់ខ្លួន ដែលត្រូវផ្តល់កិច្ចការពារឱ្យបានសមស្របចំពោះសិទ្ធិមនុស្ស និងសិទ្ធិសេរីភាព ជាពិសេសសិទ្ធិដែលមានចែងក្នុងបញ្ញើកាតព្វកិច្ច ដែលភាគីនោះបានតាក់តែងឡើងស្របតាមអនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ក្រុមប្រឹក្សាអឺរ៉ុប (១៩៥០) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិល និងនយោបាយរបស់អង្គការសហប្រជាជាតិ (១៩៦៦) ឬឧបករណ៍ច្បាប់អន្តរជាតិផ្សេងៗទៀតដែលអាចអនុវត្តបានទាក់ទិននឹងសិទ្ធិមនុស្ស និងដែលត្រូវបានបញ្ចូលទៅក្នុងគោលការណ៍ស្តីពីការស្មើភាពគ្នា។

២ នៅពេលដែលវាមានលក្ខណៈសមស្រប គិតតាមប្រភេទនីតិវិធី ឬសិទ្ធិអំណាចពាក់ព័ន្ធ លក្ខខណ្ឌ និងការការពារទាំងនោះមានបូកបញ្ចូលទាំងការត្រួតពិនិត្យផ្នែកតុលាការ ឬទម្រង់នៃការត្រួតពិនិត្យឯករាជ្យផ្សេងៗទៀត, មូលហេតុបញ្ជាក់អំពីការអនុវត្ត រួមទាំងការកម្រិតព្រំដែននៃការអនុវត្ត និងអាជ្ញាយុកាលនៃសិទ្ធិអំណាច ឬអាជ្ញាយុកាលនៃនីតិវិធីនោះ។

៣ នៅពេលដែលវាស្របនឹងផលប្រយោជន៍សាធារណៈ ជាពិសេសស្របទៅនឹងការគ្រប់គ្រងល្អនៃប្រព័ន្ធតុលាការ ភាគីនីមួយៗពិនិត្យមើលវិសាលភាពនៃសិទ្ធិអំណាច និងនីតិវិធីនៅក្នុងជំពូកស្តីពីសិទ្ធិ ទំនួលខុសត្រូវ និងផលប្រយោជន៍ស្របច្បាប់របស់តតិយជន។

# ចំណងជើងទី២ - ការថែរក្សាជាបន្ទាន់នូវទិន្នន័យព័ត៌មានវិទ្យាដែលស្តុកទុក

## មាត្រា១៦ - ការថែរក្សាជាបន្ទាន់នូវទិន្នន័យព័ត៌មានវិទ្យាដែលស្តុកទុក

១ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតឃើញថាចាំបាច់ ដើម្បីឱ្យអាជ្ញាធរអាចមានសមត្ថកិច្ចបញ្ជា ឬបញ្ជាឱ្យធ្វើការរក្សាជាបន្ទាន់នូវទិន្នន័យព័ត៌មានវិទ្យាពិសេសៗ បូករួមទាំងទិន្នន័យទាក់ទិននឹងចរាចរណ៍ ដែលស្តុកទុកដោយប្រើប្រព័ន្ធព័ត៌មានវិទ្យា ជាពិសេសនៅពេលមានហេតុផលឱ្យគេគិតជាពិសេសថាទិន្នន័យទាំងនោះអាចបាត់បង់ ឬប្រែប្រួល។

២ នៅពេលដែលភាគីមួយអនុវត្តកថាខណ្ឌទី១ ខាងលើ ដោយដាក់បញ្ជាឱ្យមនុស្សម្នាក់ថែរក្សាទិន្នន័យស្តុកទុកពិសេសដែលស្ថិតក្រោមការកាន់កាប់របស់គេ ឬក្រោមការគ្រប់គ្រងរបស់គេ ភាគីនោះអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតឃើញថាចាំបាច់ ដើម្បីតម្រូវឱ្យបុគ្គលនោះរក្សា និងការពារបូរណភាពរបស់ទិន្នន័យក្នុងរយៈពេលចាំបាច់ណាមួយ លើសពី ៩០ ថ្ងៃ ដើម្បីឱ្យអាជ្ញាធរមានសមត្ថកិច្ចរៀបចំបញ្ជូន។ ភាគីមួយអាចចែងថា បញ្ជាបែបនេះអាចអាចបន្តបានថែមទៀតនៅពេលក្រោយមក។

៣ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតឃើញថាចាំបាច់ ដើម្បីតម្រូវឱ្យអ្នករក្សាទិន្នន័យ ឬបុគ្គលម្នាក់ផ្សេងទៀតដែលទទួលបន្ទុករក្សាទិន្នន័យ រក្សាអាថ៌កំបាំងស្តីពីការអនុវត្តនីតិវិធីក្នុងរយៈពេលកំណត់តាមច្បាប់ក្នុងស្រុក។

៤ សិទ្ធិអំណាច និងនីតិវិធីចែងក្នុងមាត្រានេះត្រូវតែគោរពទៅតាមមាត្រា១៤ និង១៥។

## មាត្រា១៧ - ការរក្សា និងបញ្ជូនដោយអន្លើឱ្យបានឆាប់រហ័សនូវទិន្នន័យទាក់ទិននឹងចរាចរណ៍

១ ដើម្បីធានាការរក្សាទិន្នន័យទាក់ទិននឹងចរាចរណ៍ ស្របតាមមាត្រា១៦ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតឃើញថាចាំបាច់៖

ក ដើម្បីធ្វើយ៉ាងណាឱ្យមានការថែរក្សាជាបន្ទាន់នូវទិន្នន័យទាក់ទិននឹងចរាចរណ៍ ដែលអ្នកផ្គត់ផ្គង់សេវាកម្មមួយឬច្រើនបានចូលរួមក្នុងការផ្សព្វផ្សាយសេចក្តីប្រកាសព័ត៌មាន និង

ខ ដើម្បីធានាមានការបញ្ជូនឱ្យបានឆាប់រហ័សដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគី ឬដោយបុគ្គលម្នាក់ដែលអាជ្ញាធរចាត់តាំង ដែលមានចំនួនទិន្នន័យគ្រប់គ្រាន់ទាក់ទិននឹងចរាចរណ៍ ដើម្បីឱ្យភាគីអាចកំណត់អត្តសញ្ញាណរបស់អ្នកផ្គត់ផ្គង់សេវាកម្ម និងមធ្យោបាយដែលគេប្រើសម្រាប់បញ្ជូនទិន្នន័យ។

២ សិទ្ធិអំណាច និងនីតិវិធីលើកឡើងក្នុងមាត្រានេះត្រូវតែគោរពទៅតាមមាត្រា១៤ និង១៥។

## ចំណងជើងទី៣ - ការបញ្ជាផលិត

### មាត្រា១៨ - ការបញ្ជាផលិត

១ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតឃើញថាចាំបាច់ដើម្បីផ្តល់អំណាចឱ្យអាជ្ញាធរមានសមត្ថកិច្ចដាក់បញ្ជា៖

ក ទៅបុគ្គលម្នាក់ដែលមានវត្តមាននៅលើដែនដីរបស់ខ្លួន ឱ្យបញ្ជូនទិន្នន័យព័ត៌មានវិទ្យាពិសេស ដែលខ្លួនកាន់កាប់ឬដែលស្ថិតក្រោមការត្រួតពិនិត្យរបស់ខ្លួន ដែលត្រូវបានស្តុកទុកក្នុងប្រព័ន្ធព័ត៌មានវិទ្យា ឬឧបករណ៍ស្តុកទិន្នន័យ និង

ខ ទៅអ្នកផ្គត់ផ្គង់ដែលផ្តល់សេវាកម្មនៅលើដែនដីរបស់ភាគី ឱ្យបញ្ជូនទិន្នន័យដែលស្ថិតក្រោមការកាន់កាប់ ឬក្រោមការត្រួតពិនិត្យរបស់ខ្លួនទាក់ទិននឹងអតិថិជន និងទាក់ទិននឹងសេវាកម្មនោះ។

២ សិទ្ធិអំណាច និងនីតិវិធីលើកឡើងក្នុងមាត្រានេះត្រូវស្របទៅតាមមាត្រា១៤ និង១៥។

៣ សម្រាប់មាត្រានេះ ពាក្យថា «ទិន្នន័យពាក់ព័ន្ធនឹងអ្នកជាវ» សំដៅលើរាល់ព័ត៌មាន ក្រោមទម្រង់ជាទិន្នន័យព័ត៌មានវិទ្យា ឬក្រោមទម្រង់ផ្សេងៗទៀត ដែលអ្នកផ្តល់សេវាកម្មកាន់កាប់ និងជាប់ពាក់ព័ន្ធនឹងអ្នកជាវសេវាកម្ម ក្រៅពីទិន្នន័យទាក់ទិននឹងចរាចរណ៍ ឬខ្លឹមសារ និងអាចអនុញ្ញាតឱ្យគេរៀបចំ៖

ក ប្រភេទសេវាកម្មទំនាក់ទំនងសម្រាប់ប្រើប្រាស់ ឧបករណ៍បច្ចេកទេសសម្រាប់ផ្តល់សេវាកម្ម និងរយៈពេលសេវាកម្ម

ខ អត្តសញ្ញាណ អាសយដ្ឋានប្រៃសណីយ៍ ឬទីតាំងភូមិសាស្ត្រ និងលេខទូរស័ព្ទរបស់អ្នកជាវ និងលេខផ្សេងទៀតសម្រាប់ទំនាក់ទំនង ទិន្នន័យទាក់ទិននឹងការចេញវិក្កយបត្រ និងការចំណាយដែលអាចប្រើបានដោយសម្អាងលើកិច្ចសន្យា និងការរៀបចំសេវាកម្ម។

គ រាល់ព័ត៌មានផ្សេងទៀតទាក់ទិននឹងទីកន្លែងដែលបរិក្ខារសម្រាប់ទំនាក់ទំនងស្ថិតនៅ អាចយកមកប្រើបានដោយផ្អែកលើកិច្ចសន្យា និងការរៀបចំសេវាកម្ម។

## ចំណងជើងទី៤ - ការឆែកឆេរ និងរឹបអូសទិន្នន័យព័ត៌មានវិទ្យាដែលស្តុកទុក

### មាត្រា១៩ - ការឆែកឆេរ និងរឹបអូសទិន្នន័យព័ត៌មានវិទ្យាដែលស្តុកទុក

១ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងដែលខ្លួនគិតឃើញថាចាំបាច់ ដើម្បីឱ្យអាជ្ញាធរមានសមត្ថកិច្ចអាចធ្វើការឆែកឆេរ ឬចូលទៅពិនិត្យមើលក្នុងលក្ខណៈស្រដៀងនេះ៖

ក នូវប្រព័ន្ធព័ត៌មានវិទ្យា ឬមួយចំណែកណាមួយនៃប្រព័ន្ធព័ត៌មានវិទ្យា រួមទាំងទិន្នន័យព័ត៌មានវិទ្យាស្តុកទុកនៅក្នុងប្រព័ន្ធព័ត៌មាននោះ និង

ខ នូវឧបករណ៍ផ្ទុកដែលអនុញ្ញាតឱ្យគេស្តុកទិន្នន័យព័ត៌មានវិទ្យានៅលើដែនដីរបស់ខ្លួន។

២ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតឃើញថាចាំបាច់ ដើម្បីឱ្យនៅពេលដែលអាជ្ញាធរឆែកឆេរ ឬចូលទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាពិសេសណាមួយ ឬមួយផ្នែកនៃប្រព័ន្ធនោះ ស្របតាមកថាខណ្ឌទី១. ក. និងមានហេតុផលនឹងគិតថាទិន្នន័យដែលខ្លួនស្វែងរកត្រូវបានស្តុកនៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាមួយផ្សេងទៀត ឬនៅក្នុងផ្នែកណាមួយនៃប្រព័ន្ធព័ត៌មានវិទ្យានោះ នៅលើដែនដីខ្លួន និងនៅពេលដែលទិន្នន័យព័ត៌មានវិទ្យាត្រូវអាចគេចូលទៅពិនិត្យមើលបានផងដែរពីប្រព័ន្ធដើម ឬប្រព័ន្ធនៅទំនេរសម្រាប់ប្រព័ន្ធដើមនេះ អាជ្ញាធរអាចមានលទ្ធភាពលាតសន្ធឹងឱ្យបានឆាប់រហ័សនូវវិធានការឆែកឆេរ ឬការចូលទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាមួយទៀតក្នុងលក្ខណៈស្រដៀងគ្នានេះ។

៣ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតឃើញថាចាំបាច់ ដើម្បីផ្តល់លទ្ធភាពឱ្យអាជ្ញាធរមានសមត្ថកិច្ចរឹបអូស ឬទទួលបានក្នុងលក្ខណៈស្រដៀងគ្នានូវទិន្នន័យព័ត៌មានវិទ្យា ដែលគេអាចចូលទៅពិនិត្យមើលបានស្របទៅតាមកថាខណ្ឌទី១ ឬទី២។ វិធានការទាំងនោះមានរួមបញ្ចូលនូវសិទ្ធិដូចខាងក្រោម៖

ក រឹបអូស ឬទទួលបានក្នុងលក្ខណៈស្រដៀងគ្នានេះនូវប្រព័ន្ធព័ត៌មានវិទ្យាមួយទាំងមូល ឬមួយផ្នែក ឬឧបករណ៍ស្តុកទិន្នន័យព័ត៌មានវិទ្យា។

ខ ធ្វើ ឬរក្សាឯកសារថតចម្លងនៃទិន្នន័យព័ត៌មានវិទ្យា

គ រក្សាបូរណភាពនៃទិន្នន័យព័ត៌មានវិទ្យាពិតប្រាកដដែលស្តុកទុក

ឃ បំបិទ ឬដកចេញនូវទិន្នន័យព័ត៌មានវិទ្យានៃប្រព័ន្ធព័ត៌មានវិទ្យាដែលគេបើកមើល។

៤ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតថាចាំបាច់ ដើម្បីឱ្យអាជ្ញាធរមានសមត្ថកិច្ចអាចដាក់បទបញ្ជាទៅបុគ្គលគ្រប់រូបដែលស្គាល់ដំណើរការប្រព័ន្ធព័ត៌មានវិទ្យា ឬវិធានការត្រូវអនុវត្តដើម្បីការពារទិន្នន័យព័ត៌មានវិទ្យាដែលប្រព័ន្ធនោះផ្ទុក ឱ្យផ្តល់រាល់ព័ត៌មានចាំបាច់សមស្រប ដើម្បីអាចឱ្យគេអនុវត្តវិធានការចែងនៅកថាខណ្ឌទី១ និងទី២។

៥ សិទ្ធិអំណាច និងនីតិវិធីចែងក្នុងមាត្រានេះត្រូវតែគោរពទៅតាមមាត្រា១៤ និង១៥។

## ចំណងជើងទី៥ - ការប្រមូលទិន្នន័យព័ត៌មានវិទ្យាទាក់ទិននឹងចរាចរណ៍គិតជាពេលវេលា

## មាត្រា២០ - ការប្រមូលទិន្នន័យព័ត៌មានវិទ្យាឲ្យទាន់ពេលវេលា

១ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតថាចាំបាច់ ដើម្បីឱ្យអាជ្ញាធរមានសមត្ថកិច្ចមានអំណាចក្នុងការៈ

ក ប្រមូល ឬថតទុកដោយប្រើមធ្យោបាយបច្ចេកទេសដែលមាននៅលើដែនដីរបស់ខ្លួន និង

ខ ដាក់បញ្ជាដល់អ្នកផ្តល់សេវាកម្មម្នាក់ ក្នុងក្របខណ្ឌនៃសមត្ថភាពបច្ចេកទេសដែលគេមានៈ

i ឱ្យប្រមូល ឬថតទុកដោយប្រើមធ្យោបាយបច្ចេកទេសដែលមាននៅលើដែនដីរបស់ខ្លួនឬ

ii ឱ្យផ្តល់កិច្ចសហការជ្រោមជ្រែងក្នុងការប្រមូល ឬថតទុក

ឲ្យទាន់ពេលវេលា នូវទិន្នន័យទាក់ទិននឹងចរាចរណ៍ទាក់ទិននឹងទំនាក់ទំនងពិសេស ដែលធ្វើឡើងនៅលើដែនដីរបស់ខ្លួនតាមរយៈប្រព័ន្ធព័ត៌មានវិទ្យាមួយ។

២ ខណៈដែលភាគីមួយមិនអាចអនុម័តវិធានការចែងនៅក្នុងកថាខណ្ឌទី១.ក បាន ដោយសារតែគោលការណ៍កំណត់នៅក្នុងច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីនោះអាច អនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតថាចាំបាច់ដើម្បីធានាដល់ការប្រមូល ឬថតទុកឲ្យទាន់ពេលវេលានូវទិន្នន័យទាក់ទិននឹងចរាចរណ៍ទាក់ទិននឹងទំនាក់ទំនងពិសេសដែលធ្វើឡើងនៅលើដែនដីរបស់ខ្លួន ដោយប្រើមធ្យោបាយដែលមាននៅលើដែនដីរបស់ខ្លួន។

៣ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតថាចាំបាច់ ដើម្បីតម្រូវឱ្យអ្នកផ្គត់ផ្គង់សេវាកម្មរក្សាជាសម្ងាត់នូវការអនុវត្តសិទ្ធិអំណាចណាមួយដែលមានចែងក្នុងមាត្រានេះ ព្រមទាំងព័ត៌មានទាំងអស់ដែលពាក់ព័ន្ធនឹងវា។

៤ សិទ្ធិអំណាច និងនីតិវិធីចែងក្នុងមាត្រានេះត្រូវតែគោរពតាមមាត្រា១៤ និង១៥។

## មាត្រា២១ - ការចាប់ទិន្នន័យពាក់ព័ន្ធនឹងខ្លឹមសារ

១ ភាគីនីមួយៗចាត់វិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតឃើញថាចាំបាច់ ដើម្បីផ្តល់អំណាចដល់អាជ្ញាធរមានសមត្ថកិច្ចទាក់ទិននឹងបទល្មើសធ្ងន់ធ្ងរកំណត់ឡើងដោយអនុលោមទៅតាមច្បាប់ក្នុងស្រុករបស់ខ្លួនៈ

ក ក្នុងការប្រមូល នឹងថតទុកដោយប្រើប្រាស់មធ្យោបាយដែលមាននៅលើដែនដីរបស់ខ្លួន និង

ខ ក្នុងការតម្រូវឱ្យអ្នកផ្គត់ផ្គង់សេវាកម្ម ក្នុងក្របខណ្ឌសមត្ថភាពរបស់ខ្លួនៈ

i ប្រមូល និងថតទុកដោយប្រើប្រាស់មធ្យោបាយបច្ចេកទេសដែលមាននៅលើដែនដីរបស់ខ្លួន ឬ

ii ជួយជ្រោមជ្រែងអាជ្ញាធរមានសមត្ថកិច្ចដើម្បីប្រមូល ឬចតទុក

ឲ្យទាន់ពេលវេលា នូវទិន្នន័យទាក់ទិននឹងខ្លឹមសារនៃទំនាក់ទំនងពិសេសមួយនៅលើដែនដីរបស់ខ្លួន ដែលបញ្ជូនតាមប្រព័ន្ធព័ត៌មានវិទ្យាណាមួយ។

២ ខណៈដែលភាគីមួយមិនអាចអនុម័តវិធានការកំណត់ក្នុងកថាខណ្ឌទី១.ក ដោយសារតែគោលការណ៍ចែងក្នុងច្បាប់របស់ខ្លួន ភាគីនោះអាចអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតថាចាំបាច់ ដើម្បីធានាឱ្យមានការប្រមូល ឬចតទុកឲ្យទាន់ពេលវេលានូវទិន្នន័យទាក់ទិននឹងខ្លឹមសារនៃទំនាក់ទំនងពិសេសធ្វើឡើងនៅលើដែនដីរបស់ខ្លួន តាមមធ្យោបាយបច្ចេកទេសដែលមាននៅលើដែនដីនោះ។

៣ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដើម្បីតម្រូវឱ្យអ្នកផ្គត់ផ្គង់សេវាកម្មរក្សាជាសម្ងាត់នូវការអនុវត្តសិទ្ធិអំណាចណាមួយក្នុងចំណោមសិទ្ធិអំណាចចែងក្នុងមាត្រានេះ បូករួមទាំងរាល់ព័ត៌មានទាក់ទិននឹងរឿងនេះ។

៤ សិទ្ធិអំណាច និងនីតិវិធីលើកឡើងក្នុងមាត្រានេះត្រូវតែស្របទៅតាមមាត្រា១៤ និង១៥។

# ផ្នែកទី៣ - សមត្ថកិច្ច

## មាត្រា២២ - សមត្ថកិច្ច

១ ភាគីនីមួយៗអនុម័តវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតថាចាំបាច់ ដើម្បីរៀបចំឱ្យមានសមត្ថកិច្ចផ្ទាល់ខ្លួន សម្រាប់រាល់បទល្មើសព្រហ្មទណ្ឌកំណត់ឡើងអនុលោមទៅតាមមាត្រា២ ដល់ទី១១ នៃអនុសញ្ញានេះ នៅពេលបទល្មើសត្រូវបានប្រព្រឹត្តឡើង៖

ក នៅលើដែនដីរបស់ខ្លួន ឬ

ខ នៅលើនាវាដាក់ទង់ជាតិរបស់ភាគីនោះ ឬ

គ នៅលើយន្តហោះពាក់ស្លាកលេខសម្គាល់ទៅតាមច្បាប់របស់ភាគីនោះ ឬ

ឃ ដោយជនជាតិរបស់ខ្លួនម្នាក់រស់នៅក្រៅប្រទេស ប្រសិនបើបទល្មើសនោះអាចកាត់ទោសបានជាលក្ខណៈព្រហ្មទណ្ឌនៅនឹងកន្លែងដែលគេប្រព្រឹត្ត ឬប្រសិនបើបទល្មើសនោះមិនស្ថិតនៅក្រោមសមត្ថកិច្ចដែនដីរបស់រដ្ឋណាមួយទេ។

២ ភាគីនីមួយៗអាចរក្សាសិទ្ធិមិនអនុវត្ត ឬក្នុងករណី ឬលក្ខខណ្ឌពិសេសណាមួយ អនុវត្តបទបញ្ញាស្ដីពីសមត្ថកិច្ចកំណត់ឡើងនៅមាត្រាទី១.ខ ដល់ទី១.ឃ នៃមាត្រានេះ ឬក្នុងផ្នែកណាមួយនៃកថាខណ្ឌអស់ទាំងនេះ។

៣ ភាគីនីមួយៗអនុម័តវិធានការដែលខ្លួនយល់ឃើញថាចាំបាច់ ដើម្បីបង្កើតឱ្យមានសមត្ថកិច្ចសម្រាប់រាល់បទល្មើសលើកឡើងនៅមាត្រា២៤ កថាខណ្ឌទី១ នៃអនុសញ្ញានេះ នៅពេលដែលជនជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសនោះមានវត្តមាននៅលើដែនដីរបស់ខ្លួន និងមិនអាចត្រូវបានចាប់បញ្ជូនខ្លួនឆ្ពោះទៅកាន់ទឹកដីរបស់ភាគីមួយទៀតដោយសម្អាងត្រឹមតែលើសញ្ជាតិរបស់ជននោះ បន្ទាប់ពីមានការស្នើសុំធ្វើបត្យាប័ន។

៤ អនុសញ្ញានេះពុំរាប់បញ្ចូលសមត្ថកិច្ចផ្នែកព្រហ្មទណ្ឌណាមួយកំណត់ដោយច្បាប់ក្នុងស្រុករបស់ភាគីណាមួយឡើយ។

៥ នៅពេលដែលភាគីច្រើនទាមទារឱ្យមានសមត្ថកិច្ចមួយសម្រាប់បទល្មើសដែលគេសង្ស័យដូចមានចែងក្នុងអនុសញ្ញានេះ ភាគីពាក់ព័ន្ធពិគ្រោះយោបល់គ្នា ក្នុងឱកាសសមស្រប ដើម្បីកំណត់ឱ្យបានកាន់តែច្បាស់ថាតើត្រូវធ្វើដូចម្តេចដើម្បីធ្វើការចោទប្រកាន់។

# ជំពូកទី៣ - កិច្ចសហប្រតិបត្តិការអន្តរជាតិ

## ផ្នែកទី១ - គោលការណ៍ទូទៅ

### ចំណងជើងទី១ - គោលការណ៍ទូទៅទាក់ទិននឹងសហប្រតិបត្តិការអន្តរជាតិ

#### មាត្រា២៣ - គោលការណ៍ទូទៅទាក់ទិននឹងសហប្រតិបត្តិការអន្តរជាតិ

ភាគីទាំងអស់ធ្វើកិច្ចសហប្រតិបត្តិជាមួយគ្នា អនុលោមទៅតាមបញ្ញត្តិនៃជំពូកនេះ ដោយអនុវត្តឧបករណ៍ច្បាប់អន្តរជាតិស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិទាក់ទិននឹងបទល្មើសព្រហ្មទណ្ឌ, កិច្ចព្រមព្រៀងផ្អែកលើនីតិប្បញ្ញត្តិដូចគ្នានេះ ឬឆ្លើយតបឱ្យគ្នាទៅវិញទៅមក និងច្បាប់ជាតិរបស់ខ្លួន ឱ្យបានទូលំទូលាយតាមតែអាចធ្វើទៅបាន សម្រាប់ការស៊ើបអង្កេត ឬនីតិវិធីទាក់ទិននឹងបទល្មើសព្រហ្មទណ្ឌពាក់ព័ន្ធនឹងប្រព័ន្ធនឹងប្រព័ន្ធព័ត៌មានវិទ្យា និងទិន្នន័យព័ត៌មានវិទ្យា ឬដើម្បីប្រមូលភស្តុតាងលក្ខណៈអេឡិចត្រូនិកនៃបទល្មើសព្រហ្មទណ្ឌ ។

### ចំណងជើងទី២ - គោលការទាក់ទិននឹងបត្យាប័ន

#### មាត្រា២៤ - បត្យាប័ន

១ ក មាត្រានេះពាក់ព័ន្ធនឹងបត្យាប័នរវាងភាគីផ្សេងៗចំពោះបទល្មើសព្រហ្មទណ្ឌកំណត់ឡើងស្របតាមមាត្រា១ ដល់ទី១១ នៃអនុសញ្ញានេះ ក្នុងករណីដែលបទល្មើសទាំងនោះអាចថ្កោលទោសបាននៅតាមនីតិប្បញ្ញត្តិនៃភាគីទាំងពីរ ដែលជាប់ពាក់ព័ន្ធនឹងទោសដកហូតសិទ្ធិសេរីភាពសម្រាប់រយៈពេលលើសពីមួយឆ្នាំ ឬទោសធ្ងន់ជាងនេះ។

ខ នៅពេលមានការទាមទារឱ្យមានទោសអប្បបរមាមួយផ្សេងទៀត ដោយផ្អែកលើសន្ធិសញ្ញាណាមួយស្តីពីបត្យាប័ន ដែលអាចអនុវត្តបានរវាងភាគីពីរ ឬច្រើន បូករួមទាំងអនុសញ្ញាអឺរ៉ុបស្តីពីបត្យាប័ន (STE n° 24) (STE n° 24) ឬកិច្ចព្រមព្រៀងផ្អែកលើនីតិប្បញ្ញត្តិដូចគ្នា ឬឆ្លើយតបឱ្យគ្នាទៅវិញទៅមក គេត្រូវអនុវត្តទោសអប្បបរមាចែងដោយសន្ធិសញ្ញានោះ ឬដោយកិច្ចព្រមព្រៀងនោះ។

២ បទល្មើសព្រហ្មទណ្ឌបរិយាយនៅកថាខណ្ឌទី១ នៃមាត្រានេះត្រូវបានចាត់បញ្ចូលជាបទល្មើសអាចឈានទៅដល់ការធ្វើបត្យាប័ននៅក្នុងសន្ធិសញ្ញាស្តីពីបត្យាប័ន ដែលមានរវាងភាគីពីរ ឬភាគីទាំងអស់។ ភាគីទាំងអស់សន្យាចាត់បញ្ចូលបទល្មើសដែលចាត់ទុកជាបទល្មើសអាចឈានទៅដល់ការធ្វើបត្យាប័នទៅក្នុងសន្ធិសញ្ញាស្តីពីបត្យាប័នដែលអាចព្រមព្រៀងរវាងភាគីពីរ ឬភាគីទាំងអស់។

៣ នៅពេលដែលភាគីមួយអនុវត្តបត្យាប័នស្របទៅតាមសន្ធិសញ្ញាដែលមាន និងទទួលសំណើសុំធ្វើបត្យាប័នពីភាគីមួយដែលខ្លួនមិនបានចុះសន្ធិសញ្ញាជាមួយស្តីពីបត្យាប័ន ភាគីនោះអាចចាត់ទុកអនុសញ្ញានេះជាមូលដ្ឋានគតិយុត្តិសម្រាប់ការធ្វើបត្យាប័នពាក់ព័ន្ធនឹងគ្រប់បទល្មើសព្រហ្មទណ្ឌកំណត់នៅកថាខណ្ឌទី១ នៃមាត្រានេះ។

៤ ភាគីទាំងអស់ដែលមិនយកវត្តមាននៃសន្ធិសញ្ញាធ្វើជាលក្ខខណ្ឌក្នុងការអនុវត្តបត្យាប័ន ទទួលស្គាល់បទល្មើសព្រហ្មទណ្ឌចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ថាជាបទល្មើសដែលអាចឈានទៅដល់ការធ្វើបត្យាប័នរវាងភាគីទាំងនោះ។

៥ បត្យាប័នត្រូវអនុវត្តទៅតាមលក្ខខណ្ឌចែងក្នុងស្រុករបស់ភាគីត្រូវគេស្នើសុំ ឬដោយសន្ធិសញ្ញាស្តីពីបត្យាប័នជាធរមាន បូករួមទាំងហេតុផលដែលភាគីពាក់ព័ន្ធអាចបដិសេធការធ្វើបត្យាប័ន។

៦ ប្រសិនបើបត្យាប័នសម្រាប់បទល្មើសព្រហ្មទណ្ឌមួយលើកឡើងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ត្រូវបានបដិសេធដោយសម្អាងត្រឹមតែលើសញ្ជាតិរបស់បុគ្គលដែលគេស្វែងរកចាប់ខ្លួន ឬព្រោះតែថាភាគីដែលគេស្នើសុំនោះរំពឹងថាខ្លួនមានសមត្ថកិច្ចលើបទល្មើសនោះ ភាគីដែលគេស្នើសុំនោះត្រូវប្រគល់សំណុំរឿងខាងលើតាមសំណើរបស់ភាគីស្នើសុំ ទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនដើម្បីធ្វើការចោទប្រកាន់ និងក្នុងពេលចាំបាច់ ត្រូវប្រគល់រឿងក្តីទៅឱ្យភាគីដែលស្នើសុំជាអ្នកដោះស្រាយ។ អាជ្ញាធរមានសមត្ថកិច្ចនោះនឹងធ្វើសេចក្តីសម្រេច និងធ្វើការស៊ើបអង្កេត និងចាត់នីតិវិធីដូចគ្នាដើម្បីឱ្យរាល់បទល្មើសផ្សេងទៀតប្រភេទនេះអនុលោមទៅតាមនីតិប្បញ្ញត្តិរបស់ខ្លួន។

៧ ក ភាគីនីមួយៗបញ្ជូនទៅឱ្យអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអឺរ៉ុប នៅពេលចុះហត្ថលេខា ឬនៅពេលដាក់តម្កល់លិខិតូបករណ៍ស្តីពីសច្ចាប័ន ការយល់ព្រម ឯកភាព ឬការចូលជាសមាជិក នូវឈ្មោះ និងអាសយដ្ឋានរបស់អាជ្ញាធរមានសមត្ថកិច្ចនីមួយៗដែលទទួលខុសត្រូវធ្វើ ឬទទួលឯកសារស្នើសុំការធ្វើបត្យាប័ន ឬឃាត់ខ្លួនបណ្តោះអាសន្ន ពេលណាពុំមានសន្ធិសញ្ញា។

ខ អគ្គលេខាធិការដ្ឋានត្រូវកំណត់ ឬធ្វើបច្ចុប្បន្នភាពលើបញ្ជីរាយឈ្មោះអាជ្ញាធរមានសមត្ថកិច្ចដែលភាគីទាំងអស់ចាត់តាំង។ ភាគីនីមួយៗត្រូវធ្វើយ៉ាងណាឱ្យទិន្នន័យនៅក្នុងបញ្ជីមានភាពជាក់លាក់ជាអចិន្ត្រៃយ៍។

## ចំណងជើងទី៣ - គោលការណ៍ទូទៅទាក់ទិននឹងកិច្ចសហការគ្នា

### មាត្រា២៥ - គោលការណ៍ទូទៅទាក់ទិននឹងកិច្ចសហការគ្នា

១ ភាគីទាំងអស់ព្រមព្រៀងនឹងជួយគ្នាទៅវិញទៅមកឱ្យបានទូលំទូលាយតាមតែអាចធ្វើទៅបានពាក់ព័ន្ធនឹងការស៊ើបអង្កេត ឬនីតិវិធីស្ដីពីបទល្មើសព្រហ្មទណ្ឌទាក់ទិននឹងប្រព័ន្ធព័ត៌មានវិទ្យា និងទិន្នន័យព័ត៌មានវិទ្យា ឬដើម្បីប្រមូលភស្តុតាងលក្ខណៈអេឡិចត្រូនិកនៃបទល្មើសព្រហ្មទណ្ឌ។

២ ភាគីនីមួយៗអនុម័តផងដែរនូវវិធានការនីតិប្បញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលខ្លួនគិតថាចាំបាច់ដើម្បីបំពេញកាតព្វកិច្ចដែលប្រកាសនៅមាត្រា២៧ និង៣៥។

៣ ក្នុងករណីចាំបាច់ ភាគីនីមួយៗអាចធ្វើការស្នើសុំជំនួយ ឬទំនាក់ទំនងដោយប្រើមធ្យោបាយទាក់ទងរហ័ស ដូចជាទូរសារ ឬអ៊ីមែល ហើយមធ្យោបាយទាំងនោះត្រូវតែមានសុវត្ថិភាព និងមានលក្ខណៈគ្រប់គ្រាន់ (បើចាំបាច់ ត្រូវមានទាំងកម្មវិធីសម្រាប់អានឯកសារទាំងនោះផង) ជាមួយនឹងសេចក្ដីបញ្ជាក់ផ្លូវការនៅពេលបន្ទាប់ប្រសិនបើរដ្ឋដែលគេស្នើសុំនោះទាមទារសុំ។ រដ្ឋដែលត្រូវគេស្នើសុំនោះព្រមទទួលពាក្យសុំ ហើយឆ្លើយតបទៅវិញតាមមធ្យោបាយមួយក្នុងចំណោមមធ្យោបាយទាក់ទងទាំងប៉ុន្មានខាងលើ។

៤ លើកលែងតែបញ្ញត្តិផ្ទុយជាផ្លូវការចែងក្នុងមាត្រាផ្សេងៗនៃជំពូកនេះ ពុំនោះទេការផ្ដល់ជំនួយត្រូវគោរពតាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ក្នុងស្រុករបស់ភាគី ដែលគេស្នើសុំ ឬ ដោយសន្ធិសញ្ញាស្ដីពីកិច្ចសហការគ្នាដែលអាចយកមក អនុវត្តបានបូករួមទាំងមូលហេតុដែលភាគីត្រូវគេស្នើសុំអាចបដិសេធមិនសហការ។ ភាគីដែលត្រូវគេស្នើសុំកិច្ចសហការទាក់ទិននឹងបទល្មើសចែងក្នុងមាត្រា២ ដល់ទី១១ ដោយសារមូលហេតុ ថាការស្នើសុំនោះពាក់ព័ន្ធនឹងបទល្មើស ដែលខ្លួនចាត់ទុកថាជាប្រភេទបទល្មើសសារពើពន្ធ។

៥ អនុលោមទៅតាមជំពូកនេះ ខណៈដែលភាគីដែលគេស្នើសុំត្រូវបានអនុញ្ញាតឱ្យជួយជ្រោមជ្រែងនៅពេលមានការចោទប្រកាន់ពីរទន្ទឹមគ្នា លក្ខខណ្ឌនេះនឹងត្រូវចាត់ទុកថាគ្រប់គ្រាន់ ប្រសិនបើឥរិយាបថបង្កបទល្មើស ដែលគេស្នើសុំកិច្ចសហការ ត្រូវបានវាយតម្លៃថាជាបទល្មើសព្រហ្មទណ្ឌដោយច្បាប់ក្នុងស្រុករបស់ខ្លួន នៅពេលដែលច្បាប់ក្នុងស្រុករបស់ខ្លួនចាត់ ឬមិនចាត់បទល្មើសនោះទៅក្នុងប្រភេទបទល្មើសតែមួយ ឬនៅពេលដែលច្បាប់នោះហៅបទល្មើសនោះ ឬមិនហៅបទល្មើសនោះដោយប្រើវាក្យសព្ទដូចក្នុងច្បាប់របស់ភាគីស្នើដែលស្នើសុំកិច្ចសហការ។

### មាត្រា២៦ – ព័ត៌មានដែលកើតឡើងដោយឯងៗ

១ អាស្រ័យដោយកំហិតនៃច្បាប់ក្នុងប្រទេស និងដោយសារគ្មានការស្នើសុំជាមុន ភាគីមួយអាចផ្តល់ទៅភាគីមួយទៀត នូវព័ត៌មានដែលទទួលបាន ក្នុងក្របខណ្ឌនៃការអង្កេតផ្ទាល់ខ្លួន នៅពេលដែលភាគីនោះវាយតម្លៃថាវាអាចជួយដល់ភាគីទទួលព័ត៌មាន ក្នុងការចូលរួមឬដឹកនាំការអង្កេត ឬនីតិវិធី ទាក់ទងទៅនឹងបទល្មើសព្រហ្មទណ្ឌដែលធ្វើឡើង ដោយអនុលោមទៅតាមអនុសញ្ញានេះ ឬនៅពេលដែលព័ត៌មានអាចនាំឲ្យមានការស្នើសុំសហប្រតិបត្តិការដែលតាក់តែងឡើងដោយភាគីនេះ នៅក្នុងជំពូកនេះ។

២ មុននឹងបញ្ជូនព័ត៌មានបែបនោះ ភាគីដែលផ្តល់ព័ត៌មាន អាចស្នើសុំឲ្យព័ត៌មានទាំងនោះមានលក្ខណៈជាការសម្ងាត់ ឬសុំឲ្យការប្រើប្រាស់ព័ត៌មានទាំងនោះតែក្នុងលក្ខខណ្ឌខ្លះៗតែប៉ុណ្ណោះ។ បើភាគីទទួលព័ត៌មានមិនអាចឆ្លើយតបទៅនឹងការស្នើសុំនោះទេ ភាគីនេះត្រូវផ្តល់ដំណឹងជូនភាគីម្ខាងទៀតដែលជាអ្នកកំណត់ថាតើគួរតែបញ្ជូនព័ត៌មាននោះដែរឬទេ។ ប្រសិនបើភាគីទទួលព័ត៌មានព្រមទទួលយកលក្ខខណ្ឌដែលបានកំណត់ ភាគីនេះត្រូវស្ថិតនៅក្រោមលក្ខខណ្ឌទាំងនោះ។

## ផ្នែកទី៤ –នីតិវិធីពាក់ព័ន្ធទៅនឹងកិច្ចសហការគ្នាប្រសិនបើគ្មានកិច្ចព្រមព្រៀងអន្តរជាតិដែលយកទៅអនុវត្តបាន

### មាត្រា២៧ – នីតិវិធីពាក់ព័ន្ធទៅនឹងការជួយគ្នាទៅវិញទៅមក ប្រសិនបើគ្មានកិច្ចព្រមព្រៀងអន្តរជាតិដែលយកទៅអនុវត្តបាន

១ ដោយសារគ្មានសន្ធិសញ្ញាស្តីពីកិច្ចសហការគ្នា ឬកិច្ចព្រមព្រៀងគ្នាដែលផ្អែកទៅលើយុត្តិការឯកច្ឆ័ន្ទ ឬឆ្លើយតបគ្នាទៅវិញទៅមក ដែលមានជាធរមានរវាងភាគីស្នើសុំ និងភាគីទទួលការស្នើសុំ បទប្បញ្ញត្តិពីកថាខណ្ឌទី២ ដល់ទី៩ នៃមាត្រានេះអាចយកទៅអនុវត្តបាន។ បទប្បញ្ញត្តិទាំងនេះមិនអនុវត្ត នៅក្នុងករណីដែលសន្ធិសញ្ញាមួយ វិធានការមួយ ឬច្បាប់បែបនេះមានអត្ថិភាព លើកលែងតែភាគីពាក់ព័ន្ធសម្រេចថាអនុវត្តទាំងស្រុង ឬមួយផ្នែកជំនួសផ្នែកផ្សេងទៀតនៃមាត្រានេះ ។

២ ក- ភាគីនីមួយៗចាត់តាំងអាជ្ញាធរកណ្តាលមួយ ឬច្រើនឲ្យទទួលបន្ទុកបញ្ជូនពាក្យសុំកិច្ចសហការគ្នា ឬឆ្លើយតបទៅនឹងការស្នើសុំនោះ អនុវត្ត ឬបញ្ជូនការស្នើសុំទៅកាន់អាជ្ញាធរមានសមត្ថកិច្ចដើម្បីអនុវត្ត។

ខ- អាជ្ញាធរកណ្តាលជាអ្នកភ្ជាប់ទំនាក់ទំនងពីភាគីមួយទៅភាគីមួយទៀតដោយផ្ទាល់។

គ- នៅក្នុងខណៈចុះហត្ថលេខា ឬដាក់លិខិតូបករណ៍ សម្រាប់ធ្វើសច្ចាប័ន យល់ព្រម ទទួលយកឯកភាព ឬចូលជាសមាជិក ភាគីនីមួយៗត្រូវបានប្រគល់ជូនអគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុប នូវបញ្ជីឈ្មោះ និងអាសយដ្ឋាននៃអាជ្ញាធរដែលបានចាត់តាំងស្រាប់អនុវត្តនៅក្នុងកថាខណ្ឌនេះ។

ឃ- អគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុបត្រូវចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពនៃឈ្មោះអាជ្ញាធរកណ្តាលដែលចាត់តាំងដោយភាគីនីមួយៗ។ ភាគីនីមួយៗត្រូវធ្វើយ៉ាងណាឲ្យទិន្នន័យដែលមានក្នុងបញ្ជីមានភាពជាក់លាក់ជាអចិន្ត្រៃយ៍។

៣ ការស្នើសុំឲ្យមានការជួយអន្តរាគមន៍គ្នា ទៅតាមមាត្រានេះ ត្រូវអនុវត្តដោយអនុលោមទៅ នឹងនីតិវិធីដែលកំណត់ឡើងជាពិសេសដោយភាគីស្នើសុំ លើកលែងតែនីតិវិធីនោះមិនស្របគ្នានឹងច្បាប់នៃភាគីទទួលការស្នើសុំ។

៤ ក្រៅពីលក្ខខណ្ឌ ឬមូលហេតុបដិសេធ ដែលមានចែងនៅក្នុងមាត្រា២៥ កថាខណ្ឌ៤ ការជួយគ្នាទៅវិញទៅ មកនេះអាចត្រូវបដិសេធដោយភាគីទទួលការស្នើសុំ៖

ក ប្រសិនបើការស្នើសុំលើកឡើងពីការប្រព្រឹត្តបទល្មើសដែលភាគីទទួលការស្នើសុំចាត់ទុកថាជាមានលក្ខណៈនយោបាយ ឬជាប់ពាក់ព័ន្ធទៅនឹងបទល្មើសនយោបាយ ឬ

ខ ប្រសិនបើភាគីទទួលការស្នើសុំវាយតម្លៃថាការទទួលយកការស្នើសុំអាចនឹងប៉ះពាល់ដល់អធិបតេយ្យភាពរបស់ខ្លួន ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ឬដល់ផលប្រយោជន៍ជាសារវន្តផ្សេងៗទៀត។

៥ ភាគីទទួលការស្នើសុំអាចលើកការស្នើសុំទៅពេលក្រោយ ប្រសិនបើការស្នើសុំនោះអាចប៉ះពាល់ដល់ការអង្កេត ឬនីតិវិធីដែលដឹកនាំធ្វើឡើងដោយអាជ្ញាធររបស់ខ្លួន។

៦ មុននឹងបដិសេធ ឬលើកពេលចំពោះកិច្ចសហប្រតិបត្តិការរបស់ខ្លួន និងក្នុងករណីចាំបាច់ បន្ទាប់ពីបានពិគ្រោះជាមួយនឹងភាគីស្នើសុំ ភាគីដែលទទួលការស្នើសុំត្រូវពិនិត្យមើលថាតើការស្នើសុំនោះមានលក្ខណៈសមស្របមួយចំណែក ឬក៏ត្រូវកំណត់លក្ខខណ្ឌដែលភាគីគិតថាចាំបាច់ថែមទៀត។

៧ ភាគីទទួលការស្នើសុំត្រូវជូនព័ត៌មានឲ្យបានឆាប់រហ័សដល់ភាគីស្នើសុំ អំពីដំណើរការបន្តដែលខ្លួនចង់បានចំពោះការស្នើសុំជួយអន្តរាគមន៍គ្នាទៅវិញទៅមក។ ភាគីទទួលការស្នើសុំត្រូវប្រាប់ពីមូលហេតុជាយថាហេតុចំពោះការបដិសេធរបស់ខ្លួនក្នុងការយល់ស្របតាមការស្នើសុំ ឬចំពោះការផ្អាកការស្នើសុំជាយថាហេតុ។ ភាគីទទួលការស្នើត្រូវផ្តល់ព័ត៌មានផងដែរជូនដល់ភាគីស្នើសុំអំពីរាល់មូលហេតុដែលនាំឲ្យមានការសុំជំនួយអន្តរាគមន៍មិនអាចធ្វើទៅបាន ឬដែលអាចពន្យឺតខ្លាំងដល់ការស្នើសុំនោះ។

៨ ភាគីស្នើសុំអាចសុំឲ្យភាគីទទួលការស្នើសុំរក្សាការសម្ងាត់សម្រាប់អង្គហេតុ ឬវត្ថុបំណងនៃរាល់ការស្នើសុំដែលធ្វើឡើងទៅតាមជំពូកនេះ លើកលែងតែក្នុងករណីចាំបាច់ក្នុងការស្នើសុំដូចរៀបរាប់នៅខាងលើនេះ។ ប្រសិនបើភាគីទទួលការស្នើមិនអាចបំពេញការស្នើសុំឲ្យរក្សាការសម្ងាត់នេះទេ ភាគីនេះត្រូវផ្តល់ព័ត៌មានឲ្យបានឆាប់រហ័សដល់ភាគីស្នើសុំ ដែលជាអ្នកកំណត់ថាតើគួរតែធ្វើការស្នើសុំនោះឬទេ។

៩ ក ក្នុងករណីបន្ទាន់ អាជ្ញាធរតុលាការនៃភាគីស្នើសុំ អាចធ្វើការស្នើសុំការជួយអន្តរាគមន៍គ្នា ឬសុំព័ត៌មានដែលទាក់ទិន ទៅកាន់សមភាគីទទួលការស្នើសុំដោយផ្ទាល់តែម្តង។ ក្នុងករណីបែបនោះ ពាក្យស្នើសុំ១ច្បាប់ត្រូវបញ្ជូនក្នុងពេលជាមួយគ្នាទៅកាន់អាជ្ញាធរកណ្តាលនៃភាគីទទួលការស្នើសុំ តាមរយៈអាជ្ញាធរកណ្តាលនៃភាគីស្នើសុំ។

ខ រាល់ការស្នើសុំ ឬព័ត៌មានដែលតាក់តែងឡើងតាមកថាខណ្ឌនេះ អាចត្រូវតាក់តែងឡើងដោយអង្គការអន្តរជាតិនៃនគរបាលផ្នែកឧក្រិដ្ឋកម្ម (អាំងទែរប៉ូល)។

គ ប្រសិនបើការស្នើសុំត្រូវបានតាក់តែងឡើងដោយអនុវត្តតាមវាក្យខណ្ឌ ក. នៃមាត្រានេះ ហើយនៅពេលដែលអាជ្ញាធរណាមួយគ្មានសមត្ថភាពក្នុងការអនុវត្ត អាជ្ញាធរនោះត្រូវបញ្ជូនទៅកាន់អាជ្ញាធរជាតិមានសមត្ថកិច្ច ហើយត្រូវជូនព័ត៌មានដោយផ្ទាល់ទៅកាន់ភាគីស្នើសុំតែម្តង។

ឃ ការស្នើសុំ ឬព័ត៌មានដែលធ្វើឡើងដោយអនុវត្តតាមកថាខណ្ឌនេះ ហើយដែលមិនប្រើវិធានការបង្ខំអាចត្រូវបញ្ជូនដោយផ្ទាល់តាមរយៈអាជ្ញាធរមានសមត្ថកិច្ចនៃភាគីស្នើសុំ ទៅកាន់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីទទួលការស្នើសុំ។

ង ភាគីនីមួយៗអាចផ្តល់ដំណឹងជូនលោកអគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុប នៅក្នុងខណៈចុះហត្ថលេខា ឬនៅក្នុងពេលដាក់ លិខិតូបករណ៍សម្រាប់ធ្វើសច្ចាប័ន យល់ព្រម ទទួលយក ឯកភាព ឬចូលជាសមាជិកឲ្យជ្រាបថា ដើម្បីទទួលបាននូវប្រសិទ្ធភាពខ្ពស់ ការស្នើសុំដែលធ្វើឡើងតាមកថាខណ្ឌនេះត្រូវបញ្ជូនទៅកាន់អាជ្ញាធរកណ្តាល។

## មាត្រា២៨ – ការសម្ងាត់ និងកំហិតនៃការប្រើប្រាស់

១ ដោយអវត្តមាននៃសន្ធិសញ្ញានៃការជួយអន្តរាគមន៍គ្នា និងកិច្ចព្រមព្រៀងគ្នាដែលផ្អែកទៅលើច្បាប់ឯកថ្ព័ន្ធ ឬច្បាប់ឆ្លើយតបគ្នាទៅវិញទៅមក ដែលត្រូវចូលជាធរមាន រវាងភាគីស្នើសុំ និងភាគីទទួលការស្នើសុំ បទប្បញ្ញត្តិនៃមាត្រានេះអាចយកទៅអនុវត្តបាន។ គេមិនអាចអនុវត្តបានឡើយ ណោពេលណាដែលសន្ធិសញ្ញាមួយ វិធានការមួយ ឬច្បាប់បែបនេះមានអត្ថិភាពនោះឡើយ លើកលែងតែសាមីភាគីទាំងអស់សម្រេចថាអនុវត្តជំនួសមាត្រានេះ ទាំងស្រុង ឬមួយផ្នែកតែប៉ុណ្ណោះ។

២ ភាគីទទួលការស្នើសុំអាចប្រគល់ព័ត៌មាន ឬសម្ភារៈ ដោយឆ្លើយទៅនឹងការស្នើសុំ ៖

ក លុះត្រាតែព័ត៌មាន ឬសម្ភារៈទាំងនោះនៅតែរក្សាការសម្ងាត់បាន នៅពេលដែលការសុំជួយអន្តរាគមន៍គ្នាមិនត្រូវបានគោរពតាម ដោយសារអវត្តមាននៃលក្ខខណ្ឌនេះ ឬ

ខ លុះត្រាតែព័ត៌មាន ឬសម្ភារៈទាំងនោះមិនត្រូវបានប្រើប្រាស់ក្នុងគោលបំណងធ្វើការអង្កេត ឬដើម្បីនីតិវិធីផ្សេងខុសពីនីតិវិធីដែលមានលើកឡើងនៅក្នុងការស្នើសុំ។

៣ ប្រសិនបើភាគីស្នើសុំមិនអាចបំពេញលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌ ដែលបានរៀបរាប់នៅក្នុងកថាខណ្ឌទី២ទេនោះ ភាគីនេះត្រូវផ្តល់ព័ត៌មានទាំងនោះឲ្យបានឆាប់រហ័សទៅកាន់ ភាគីទទួលការស្នើសុំដែលជាអ្នកកំណត់ថាតើគួរតែផ្តល់ព័ត៌មានឬទេ។ ប្រសិនបើភាគីស្នើសុំទទួលយកលក្ខខណ្ឌទាំងនេះ ភាគីនោះត្រូវជាប់កាតព្វកិច្ចនេះ។

៤ រាល់ភាគីដែលផ្តល់ព័ត៌មាន ឬសម្ភារៈដែលស្ថិតនៅក្នុងលក្ខខណ្ឌដែលបានចែងនៅក្នុងកថាខណ្ឌទី២ អាចតម្រូវឲ្យភាគីម្ខាងទៀតឲ្យបញ្ជូនសេចក្តីបញ្ជាក់ច្បាស់លាស់ ពាក់ព័ន្ធនឹងលក្ខខណ្ឌនេះ ចំពោះការប្រើប្រាស់ព័ត៌មាន ឬសម្ភារៈទាំងនោះ។

# ផ្នែកទី២ – បញ្ញត្តិពិសេសស

## ចំណងជើង១ – កិច្ចសហការគ្នាពាក់ព័ន្ធនឹងវិធានការបណ្ដោះអាសន្ន

### មាត្រា២៩ – ការរក្សាទុកទិន្នន័យព័ត៌មានវិទ្យាជាបន្ទាន់

១ ភាគីមួយអាចសុំភាគីម្ខាងទៀតឲ្យបញ្ជាឬបង្ខំឲ្យមានបែបបទផ្សេងទៀតក្នុងការរក្សាទុកឲ្យបានជាបន្ទាន់នូវទិន្នន័យដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ដែលស្ថិតនៅលើដែនដីនៃភាគីម្ខាងទៀតនោះ ហើយចំពោះទិន្នន័យទាំងនោះ ភាគីស្នើសុំមានបំណងដាក់ការស្នើសុំសហការគ្នាដើម្បីចុះឆែកឆេរ ឬប្រើប្រាស់មធ្យោបាយស្រដៀងគ្នានេះ ដើម្បីចាប់ ឬទទួលបានដោយប្រើប្រាស់មធ្យោបាយស្រដៀងគ្នានេះ ដើម្បីប្រកាសប្រាប់ពីទិន្នន័យដែលរៀបរាប់ខាងលើ។

២ ការស្នើសុំធ្វើការរក្សាដែលធ្វើឡើងដោយអនុវត្តកថាខណ្ឌទី១ ត្រូវបញ្ជាក់ច្បាស់ពី ៖

ក អាជ្ញាធរដែលសុំការរក្សាទុក

ខ បទល្មើសដែលជាកម្មវត្ថុនៃការអង្កេត ឬនីតិវិធីព្រហ្មទណ្ឌ និងការពណ៌នាពីអង្គហេតុដែលជាប់ពាក់ព័ន្ធ

គ ទិន្នន័យព័ត៌មានវិទ្យាស្តុកទុកដែលត្រូវយកមករក្សាទុក និងប្រភេទទំនាក់ទំនងរវាងទិន្នន័យទាំងនោះទៅនឹងបទល្មើស

ឃ រាល់ព័ត៌មានដែលមាន និងដែលអាចកំណត់អត្តសញ្ញាណអ្នកយាមទិន្នន័យព័ត៌មានវិទ្យាស្តុកទុក ឬកន្លែងដាក់ប្រព័ន្ធព័ត៌មានវិទ្យា

ង ភាពចាំបាច់ដែលតម្រូវឲ្យចង់ប្រើប្រាស់វិធានការថែរក្សា និង

ច ការដែលនាំឲ្យភាគីមានបំណងដាក់ការស្នើសុំការជួយអន្តរាគមន៍គ្នាដើម្បីចុះឆែកឆេរ ឬប្រើប្រាស់មធ្យោបាយស្រដៀងគ្នានេះ ដើម្បីចាប់ ឬទទួលបានដោយប្រើប្រាស់មធ្យោបាយស្រដៀងគ្នានេះ ដើម្បីប្រកាសផ្សព្វផ្សាយទិន្នន័យ។

៣ បន្ទាប់ពីទទួលបានការស្នើសុំពីភាគីម្ខាងទៀត ភាគីទទួលការស្នើសុំចាត់វិធានការសមស្រប ដើម្បីផ្តើមដោយឥតអែអង់ នូវដំណើរការថែរក្សាទិន្នន័យពិសេស ឲ្យសមស្របទៅតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន។ ដើម្បីអាចឆ្លើយតបទៅនឹងសំណើទាំងនេះបាន ការចោទប្រកាន់ទ្វេ មិនមែនជាលក្ខខណ្ឌសមស្របដែលគ្រោងទុកជាមុន ចំពោះការថែរក្សាឡើយ។

៤ ភាគីមួយដែលតម្រូវយកការចោទប្រកាន់ទ្វេធ្វើជាលក្ខខណ្ឌដើម្បីឆ្លើយតបទៅនឹងការស្នើសុំឲ្យមានកិច្ចសហការគ្នា ដើម្បីចុះឆែកឆេរ ឬប្រើប្រាស់មធ្យោបាយស្រដៀងគ្នានេះ ដើម្បីចាប់ ឬទទួលបានដោយប្រើប្រាស់មធ្យោបាយស្រដៀងគ្នានេះ ឬដើម្បីប្រកាសប្រាប់ពីទិន្នន័យអាច (ចំពោះបទល្មើសផ្សេងទៀតដែលមានចែង ដោយអនុលោមពីមាត្រា២ដល់មាត្រា១១នៃអនុសញ្ញានេះ) មានសិទ្ធិបដិសេធការស្នើសុំ

ថែរក្សា ចំពោះមាត្រានេះ ក្នុងករណីដែលភាគីនេះមានមូលហេតុក្នុងការយល់ថា លក្ខខណ្ឌនៃការចោទប្រកាន់ទ្វេមិនត្រូវបានបំពេញគ្រប់គ្រាន់ នៅក្នុងពេលប្រកាសផ្សព្វផ្សាយ។

៥ ម៉្យាងទៀត ការស្នើសុំថែរក្សាអាចត្រូវបដិសេធ ៖

ក បើគ្រាន់តែការស្នើសុំពាក់ព័ន្ធទៅនឹងបទល្មើសដែលភាគីទទួលការស្នើសុំចាត់ទុកថាមានលក្ខណៈនយោបាយ ឬជាប់ទាក់ទិនទៅនឹងបទល្មើសដែលមានលក្ខណៈនយោបាយ ឬ

ខ បើគ្រាន់តែភាគីទទួលការស្នើសុំវាយតម្លៃថា ការចូលប្រើប្រាស់ការស្នើសុំអាចប៉ះពាល់ដល់អធិបតេយ្យភាព ដល់សន្តិសុខ ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ផលប្រយោជន៍សំខាន់ៗដទៃទៀត។

៦ នៅពេលដែលភាគីទទួលការស្នើសុំវាយតម្លៃថា ការថែរក្សាធម្មតាមិនទាន់គ្រប់គ្រាន់ក្នុងការធានានូវការប្រើប្រាស់ទិន្នន័យទៅថ្ងៃអនាគត ឬប៉ះពាល់ដល់ភាពសម្ងាត់នៃការអង្កេតនៃភាគីស្នើសុំ ឬនាំឲ្យខូចខាតដល់ការអង្កេតនេះតាមបែបផ្សេងទៀត ភាគីទទួលការស្នើសុំត្រូវផ្តល់ព័ត៌មានខាងលើនេះឲ្យបានឆាប់រហ័សជូនភាគីស្នើសុំ ដែលសម្រេចចិត្តថាតើគួរតែធ្វើការស្នើសុំដែរឬទេ។

៧ រាល់ការថែរក្សាដែលធ្វើឡើងដោយឆ្លើយតបទៅនឹងការស្នើសុំដែលមានចែងនៅក្នុងកថាខណ្ឌទី១ នឹងមានតម្លៃក្នុងកំឡុងពេលយ៉ាងតិច៦០ថ្ងៃ ដើម្បីទុកលទ្ធភាពឲ្យភាគីស្នើសុំអាចដាក់ការស្នើសុំ ដើម្បីចុះឆែកឆេរ ឬប្រើប្រាស់មធ្យោបាយស្រដៀងគ្នានេះ ដើម្បីចាប់ ឬទទួលបានដោយប្រើប្រាស់មធ្យោបាយស្រដៀងគ្នានេះ ដើម្បីប្រកាសផ្សព្វផ្សាយទិន្នន័យ។ បន្ទាប់ពីទទួលបានការស្នើសុំបែបនេះរួចហើយ ទិន្នន័យត្រូវតែរក្សាទុកបន្តសិន រង់ចាំដល់ពេលអនុម័តសេចក្តីសម្រេចទាក់ទងនឹងការស្នើសុំនោះ។

## មាត្រា៣០ – ការប្រកាសប្រាប់ពីទិន្នន័យដែលរក្សាទុកឲ្យបានឆាប់រហ័ស

១ ដោយធ្វើការស្នើសុំរក្សាទិន្នន័យទាក់ទងទៅនឹងការបញ្ជូនព័ត៌មានពិសេសណាមួយ ដូចមានចែងនៅមាត្រា២៩ នៅពេលណាដែលភាគីទទួលការស្នើសុំរកឃើញថាអ្នកផ្តល់សេវាកម្មនៅក្នុងរដ្ឋនៃភាគីម្ខាងទៀតបានចូលរួមក្នុងការបញ្ជូនព័ត៌មាននេះ ភាគីទទួលការស្នើសុំត្រូវផ្សព្វផ្សាយឲ្យបានឆាប់រហ័សជូនដល់ភាគីស្នើសុំនូវបរិមាណទិន្នន័យឲ្យបានគ្រប់គ្រាន់ទាក់ទិនទៅនឹងការបញ្ជូននោះ ដើម្បីកំណត់អត្តសញ្ញាណនៃអ្នកផ្តល់សេវាកម្ម និងមធ្យោបាយដែលព័ត៌មាននោះឆ្លងកាត់។

២ ការផ្សព្វផ្សាយទិន្នន័យទាក់ទងទៅនឹងការបញ្ជូនព័ត៌មាន ដូចមានអនុវត្តនៅក្នុងកថាខណ្ឌទី១ អាចត្រូវបានបដិសេធ ៖

ក បើគ្រាន់តែការស្នើសុំពាក់ព័ន្ធទៅនឹងបទល្មើសដែលភាគីទទួលការស្នើសុំចាត់ទុកថាមានលក្ខណៈនយោបាយ ឬជាប់ទាក់ទិនទៅនឹងបទល្មើសដែលមានលក្ខណៈនយោបាយ ឬ

ខ បើគ្រាន់តែភាគីទទួលការស្នើសុំវាយតម្លៃថា ការចូលប្រើប្រាស់ការស្នើសុំអាចប៉ះពាល់ដល់អធិបតេយ្យភាព ដល់សន្តិសុខ ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ផលប្រយោជន៍សំខាន់ៗដទៃទៀត។

# ផ្នែកទី២ – កិច្ចសហការគ្នាទាក់ទងទៅនឹងអំណាចនៃការស៊ើបអង្កេត

## មាត្រា៣១– កិច្ចសហការគ្នាទាក់ទងទៅនឹងការប្រើប្រាស់ទិន្នន័យដែលស្តុកទុក

១ ភាគីមួយអាចសុំភាគីម្ខាងទៀតឲ្យចុះឆែកឆេរ ឬប្រើប្រាស់មធ្យោបាយស្រដៀងគ្នានេះ ដើម្បីចាប់ ឬទទួលបានដោយប្រើប្រាស់មធ្យោបាយស្រដៀងគ្នានេះ ដើម្បីប្រកាសផ្សព្វផ្សាយទិន្នន័យដែលរៀបរាប់ខាងលើដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ដែលស្ថិតនៅលើដែនដីនៃភាគីម្ខាងទៀតនោះ រួមទាំងទិន្នន័យដែលស្តុកទុកដោយអនុលោមទៅតាមមាត្រា២៩។

២ ភាគីទទួលការស្នើសុំធ្វើការស្នើសុំដោយអនុវត្តតាមលិខិតូបករណ៍អន្តរជាតិ កិច្ចព្រមព្រៀងគ្នា និងច្បាប់ដែលមានចែងនៅមាត្រា២៣ និងដោយអនុលោមទៅតាមបទប្បញ្ញត្តិសមស្របទៅនឹងជំពូកនេះ។

៣ ការស្នើសុំត្រូវបានធ្វើឡើងឲ្យបានយ៉ាងឆាប់បំផុត តាមតែអាចធ្វើទៅបាន ក្នុងករណីដូចតទៅ ៖

ក បើមានមូលហេតុដោយសារគេយល់ថា ទិន្នន័យសមស្របមានហានិភ័យខ្ពស់អាចត្រូវបាត់បង់ ឬអាចត្រូវកែប្រែ ឬ

ខ លិខិតូបករណ៍អន្តរជាតិ តាមវិធានការ និងច្បាប់ដែលមានចែងក្នុងកថាខណ្ឌទី២ គ្រោងទុកនូវកិច្ចសហប្រតិបត្តិការឆាប់រហ័ស។

## មាត្រា៣២ – ការប្រើប្រាស់ឆ្លងដែននូវទិន្នន័យស្តុក ដោយការព្រមព្រៀងគ្នា ឬនៅពេលដែលសាធារណជនអាចប្រើប្រាស់ទិន្នន័យទាំងនោះ

ដោយមិនចាំបាច់សុំការអនុញ្ញាតពីភាគីម្ខាងទៀត ភាគីមួយអាច ៖

ក ចូលប្រើប្រាស់ទិន្នន័យព័ត៌មានវិទ្យាស្តុកដែលទុកសម្រាប់សាធារណជន (ប្រភពបើកចំហ) ទោះជាទិន្នន័យទាំងនោះស្ថិតនៅទីតាំងភូមិសាស្ត្រណាក៏ដោយ ឬ

ខ ចូលប្រើប្រាស់ ឬទទួលទិន្នន័យព័ត៌មានវិទ្យាស្តុក (តាមរយៈប្រព័ន្ធព័ត៌មានវិទ្យាដែលស្ថិតនៅលើដែនដីខ្លួន) ដែលស្ថិតនៅក្នុងរដ្ឋមួយផ្សេង ប្រសិនបើភាគីទទួលបានការយល់ព្រមស្របច្បាប់ ឬស្ម័គ្រចិត្តពីបុគ្គលដែលច្បាប់អនុញ្ញាតឲ្យផ្សព្វផ្សាយទិន្នន័យទាំងនោះតាមរយៈប្រព័ន្ធព័ត៌មានវិទ្យា។

## មាត្រា៣៣ – កិច្ចសហការគ្នាក្នុងការប្រមូលទិន្នន័យភ្លាមៗពាក់ព័ន្ធទៅនឹងការបញ្ជូនព័ត៌មាន

១ ភាគីទាំងអស់ព្រមព្រៀងគ្នាក្នុងការប្រមូលទិន្នន័យពាក់ព័ន្ធទៅនឹងការបញ្ជូនព័ត៌មានភ្លាមៗ ទាក់ទងទៅនឹងនឹងព័ត៌មានរកឃើញនៅលើដែនដីរបស់ខ្លួន ដែលបញ្ជូនតាមរយៈប្រព័ន្ធព័ត៌មានវិទ្យា។ វៀរលែងតែ

បទប្បញ្ញត្តិនៃកថាខណ្ឌទី២ ការជួយអន្តរាគមន៍គ្នានេះអាស្រ័យទៅតាមលក្ខខណ្ឌ និងនីតិវិធីដែលមានចែងក្នុងច្បាប់ក្នុងប្រទេស។

២ ភាគីនីមួយៗយល់ព្រមជួយអន្តរាគមន៍គ្នា យ៉ាងហោចណាស់ក៏ចំពោះបទល្មើសព្រហ្មទណ្ឌដែរ រីឯការប្រមូលទិន្នន័យភ្លាមៗទាក់ទិនទៅនឹងការបញ្ជូនទិន្នន័យអាចនឹងធ្វើទៅបានសម្រាប់រឿងរ៉ាវដូចគ្នានេះនៅថ្នាក់ប្រទេស។

## មាត្រា៣៤ – ការជួយអន្តរាគមន៍គ្នាចំពោះការចាប់យកទិន្នន័យទាក់ទងនឹងខ្លឹមសារ

ភាគីទាំងអស់ព្រមព្រៀងគ្នាក្នុងការជួយអន្តរាគមន៍គ្នា ទៅតាមវិធានការដែលអនុញ្ញាតដោយសន្ធិសញ្ញា និងច្បាប់អនុវត្តផ្ទៃក្នុងនៃភាគីទាំងនោះ ដើម្បីប្រមូល ឬថតទុកភ្លាមៗនៃទិន្នន័យទាក់ទិនទៅនឹងខ្លឹមសារព័ត៌មានពិសេសដែលត្រូវបានបញ្ជូនតាមប្រព័ន្ធព័ត៌មានវិទ្យា។

# ចំណងជើងទី៣ – បណ្តាញ២៤ / ៧

## មាត្រា៣៥ – បណ្តាញ២៤ / ៧

១ ភាគីនីមួយៗប្រាប់ពីទីជួបគ្នាដែលអាចទាក់ទងគ្នាបានគ្រប់ម៉ោង គ្រប់ថ្ងៃ ដើម្បីធានាបាននូវការការជួយអន្តរាគមន៍ភ្លាមៗ ចំពោះការស៊ើបអង្កេតរកបទល្មើសព្រហ្មទណ្ឌ ទាក់ទិនទៅនឹងប្រព័ន្ធ និងទិន្នន័យព័ត៌មានវិទ្យា ឬដើម្បីប្រមូលភស្តុតាងដែលមានទម្រង់ព័ត៌មានវិទ្យានៃបទល្មើសព្រហ្មទណ្ឌ។ ការជួយអន្តរាគមន៍នេះរួមបញ្ចូលនូវការសម្រួលកិច្ចការ ឬ (ប្រសិនជាច្បាប់និងការអនុវត្តក្នុងផ្ទៃប្រទេសអនុញ្ញាត) ការអនុវត្តផ្ទាល់នូវវិធានការដូចតទៅ ៖

ក ការផ្តល់នូវដំបូន្មានបច្ចេកទេស

ខ ការរក្សាទិន្នន័យ ដោយអនុលោមទៅតាមមាត្រា២៩ និង៣០។

គ ការប្រមូលភស្តុតាង ការផ្តល់ព័ត៌មានតុលាការ និងការកំណត់ទីកន្លែងនៃជនសង្ស័យ។

២ ក ទីជួបគ្នានសភាគីមួយនឹងមានមធ្យោបាយក្នុងការឆ្លើយឆ្លងគ្នាជាមួយនឹងទីជួបគ្នានៃភាគីម្ខាងទៀត ទៅតាមនីតិវិធីរហ័ស។

ខ ប្រសិនបើទីជួបគ្នានៃភាគីមួយមិនស្ថិតនៅក្រោមឱវាទនៃអាជ្ញាធរមួយ ឬច្រើននៃភាគីនោះដែលទទួលខុសត្រូវទៅលើការជួយអន្តរាគមន៍គ្នាជាលក្ខណៈអន្តរជាតិ ឬទៅលើបត្យាប័ន ទីជួបគ្នានេះត្រូវធ្វើយ៉ាងណា ដើម្បីអាចធ្វើសកម្មភាពដោយសម្របសម្រួលជាមួយនឹងអាជ្ញាធរនោះ ឬអាជ្ញាធរទាំងនោះ ទៅតាមនីតិវិធីរហ័ស។

៣ ភាគីនីមួយៗត្រូវធ្វើយ៉ាងណាឲ្យមានបុគ្គលិកដែលទទួលការបណ្តុះបណ្តាល និងប្រដាប់ទៅដោយសម្ភារៈ ដើម្បីសម្រួលដល់ដំណើរការនៃបណ្តាញ។

# ជំពូកទី៤ – ខសន្យាបញ្ចប់

## មាត្រា៣៦ – ការចុះហត្ថលេខា និងការចូលជាធរមាន

១ អនុសញ្ញានេះបើកទូលាយឲ្យចុះហត្ថលេខាដោយរដ្ឋសមាជិកនៃក្រុមប្រឹក្សាអឺរ៉ុប និងរដ្ឋដែលមិនមែនសមាជិកដែលបានចូលរួមក្នុងការតាក់តែងអនុសញ្ញានេះឡើង។

២ អនុសញ្ញានេះត្រូវធ្វើសច្ចាប័ន ត្រូវទទួលការយល់ព្រម និងការឯកភាព។ លិខិតូបករណ៍ សម្រាប់ធ្វើសច្ចាប័ន យល់ព្រម ទទួលយក ឯកភាព ឬចូលជាសមាជិក ភាគីនីមួយៗត្រូវបានដាក់ជូនអគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុប។

៣ អនុសញ្ញានេះនឹងចូលជាធរមាននៅថ្ងៃទី១ នៃខែដែលបន្តពីការផុតកំណត់រយៈពេលបីខែ បន្ទាប់ពីរដ្ឋទាំង៥ (ដោយរាប់យ៉ាងតិចរដ្ឋទាំងបីនៃក្រុមប្រឹក្សាអឺរ៉ុប) បានយល់ព្រមតាមអនុសញ្ញា ដោយអនុលោមទៅតាមបទប្បញ្ញត្តិ នៅក្នុងកថាខណ្ឌទី១ និងទី២។

៤ ចំពោះរដ្ឋហត្ថលេខីទាំងឡាយណាដែលសម្តែងការយល់ព្រមតាមអនុសញ្ញា អនុសញ្ញានេះនឹងចូលជាធរមាននៅថ្ងៃទី១ នៃខែដែលបន្តពីការផុតកំណត់រយៈពេលបីខែ បន្ទាប់ពីការយល់ព្រមតាមអនុសញ្ញាទៅតាមបទប្បញ្ញត្តិ នៅក្នុងកថាខណ្ឌទី១ និងទី២។

## មាត្រា៣៧ – ការចុះឈ្មោះជាសមាជិកនៃអនុសញ្ញា

១ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមានរួចហើយ គណៈកម្មាធិការរដ្ឋមន្ត្រីនៃក្រុមប្រឹក្សាអឺរ៉ុប អាច (បន្ទាប់ពីបានពិគ្រោះជាមួយនឹងរដ្ឋដែលចុះកិច្ចសន្យាទៅលើអនុសញ្ញា និងទទួលបានការយល់ព្រមជាឯកច្ឆ័ន្ទ) អញ្ជើញរដ្ឋដែលមិនមែនសមាជិកក្រុមប្រឹក្សា ដែលមិនបានចូលរួមតាក់តែងអនុសញ្ញា ឲ្យចូលជាសមាជិកនៃអនុសញ្ញានេះ។ ការសម្រេចចិត្តត្រូវធ្វើឡើងតាមសម្លេងភាគច្រើនដែលមានចែងនៅក្នុងមាត្រា២០.ឃ នៃលក្ខន្តិកៈក្រុមប្រឹក្សាអឺរ៉ុប និងដោយឯកច្ឆ័ន្ទពីសំណាក់អ្នកតំណាងរដ្ឋដែលចុះកិច្ចសន្យា និងដែលមានសិទ្ធិចូលកាន់តំណែង នៅក្នុងគណៈកម្មាធិការរដ្ឋមន្ត្រី។

២ ចំពោះរដ្ឋសមាជិកនៃអនុសញ្ញា អនុលោមតាមកថាខណ្ឌទី១ ខាងលើនេះ អនុសញ្ញានឹងចូលជាធរមាននៅថ្ងៃទី១ នៃខែដែលបន្តពីការផុតកំណត់រយៈពេលបីខែ បន្ទាប់ពីថ្ងៃដាក់លិខិតូបករណ៍ចូលសមាជិកជូនអគ្គលេខានៃក្រុមប្រឹក្សាអឺរ៉ុប។

## មាត្រា៣៨ – ការអនុវត្តនៅលើដែនដី

១ រដ្ឋនីមួយៗអាច (នៅក្នុងខណៈចុះហត្ថលេខា ឬនៅខណៈដាក់លិខិតូបករណ៍ សម្រាប់ធ្វើសច្ចាប័ន យល់ព្រម ទទួលយក ឯកភាព ឬចូលជាសមាជិក) កំណត់យកដែនដីមួយ ឬច្រើនដែលត្រូវយកអនុសញ្ញានេះទៅអនុវត្ត។

២ រដ្ឋនីមួយៗអាច (នៅពេលក្រោយទៀត តាមរយៈសេចក្តីប្រកាសដែលធ្វើជូនទៅលោកអគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុប) ពន្លាតការអនុវត្តអនុសញ្ញានេះទៅកាន់ដែនដីផ្សេងទៀតដែលមានបញ្ជាក់នៅក្នុងសេចក្តី

ប្រកាសនោះ។ អនុសញ្ញានឹងចូលជាធរមានចំពោះដែនដីនេះ នៅថ្ងៃទី១នៃខែដែលបន្តពីការផុតកំណត់រយៈពេលបីខែ បន្ទាប់ពីថ្ងៃទទួលសេចក្តីប្រកាសដោយអគ្គលេខាធិការ។

៣ រាល់សេចក្តីប្រកាសដែលធ្វើឡើង ដោយអនុវត្តតាមកថាខណ្ឌទាំងពីរខាងដើមមុននេះ អាចត្រូវដកចេញចំពោះអ្វីដែលទាក់ទងទៅនឹងរាល់ដែនដីដែលកំណត់នៅក្នុងសេចក្តីប្រកាសនោះ តាមរយៈសេចក្តីជូនដំណឹងជូនលោកអគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុប។ ការដកសេចក្តីប្រកាសនេះនឹងមានសុពលភាពនៅថ្ងៃទី១នៃខែដែលបន្តពីការផុតកំណត់រយៈពេលបីខែ បន្ទាប់ពីថ្ងៃទទួលសេចក្តីជូនដំណឹងខាងលើដោយលោកអគ្គលេខាធិការ។

## មាត្រា៣៩ – ប្រសិទ្ធភាពនៃអនុសញ្ញា

១ អនុសញ្ញានេះមានគោលបំណងបំពេញបន្ថែមទៅលើសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងពហុភាគី ឬទ្វេភាគីដែលធ្លាប់អនុវត្តរវាងភាគីទាំងឡាយ រួមទាំងបទប្បញ្ញត្តិ ៖

– នៃអនុសញ្ញាអឺរ៉ុបក្នុងការធ្វើបត្យាប័ន ដែលត្រូវចុះហត្ថលេខានៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៥៧ នៅទីក្រុងប៉ារីស (STE n° 24)

– នៃអនុសញ្ញាអឺរ៉ុបក្នុងការជួយអន្តរាគមន៍គ្នាផ្នែកតុលាការព្រហ្មទណ្ឌ ដែលត្រូវចុះហត្ថលេខានៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៥៩ នៅទីក្រុងស្ត្រាស្បួរ (STE n° 30)

– នៃពិធីសារបន្ថែមទៅលើអនុសញ្ញាអឺរ៉ុបក្នុងការជួយអន្តរាគមន៍គ្នាផ្នែកតុលាការព្រហ្មទណ្ឌ ដែលត្រូវចុះហត្ថលេខានៅថ្ងៃទី១៧ ខែមិនា ឆ្នាំ១៩៧៨ នៅទីក្រុងស្ត្រាស្បួរ (STE n° 99)។

២ ប្រសិនបើភាគីពីរ ឬច្រើនបានចុះកិច្ចព្រមព្រៀងមួយ ឬសន្ធិសញ្ញាមួយទាក់ទិនទៅនឹងចំណុចដែលមានចែងនៅក្នុងអនុសញ្ញានេះ ឬមួយប្រសិនបើភាគីទាំងនោះមានទំនាក់ទំនងគ្នាអំពីប្រធានបទទាំងនេះ ឬមួយទៀតប្រសិនបើភាគីទាំងនោះចុះកិច្ចសន្យាទៅថ្ងៃអនាគត ភាគីទាំងនោះក៏មានសមត្ថភាពក្នុងការអនុវត្តកិច្ចព្រមព្រៀង ឬសន្ធិសញ្ញាខាងលើនោះ ឬក្នុងការបង្កើតទំនាក់ទំនងទៅតាមស្ថានភាពនោះជាជាងប្រើប្រាស់អនុសញ្ញានេះ។ ក៏ប៉ុន្តែ នៅពេលដែលភាគីទាំងឡាយបង្កើតទំនាក់ទំនង ពាក់ព័ន្ធទៅនឹងចំណុចដែលជាកម្មវត្ថុនៃអនុសញ្ញានេះតាមបែបផ្សេងខុសពីការគ្រោងទុក ភាគីទាំងនោះត្រូវបង្កើតទំនាក់ទំនងដោយធ្វើយ៉ាងណាឲ្យត្រូវគ្នានឹងគោលបំណង និងគោលការណ៍នៃអនុសញ្ញា។

៣ ពុំមានអ្វីនៅក្នុងអនុសញ្ញានេះដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិ ការកំហិត កាតព្វកិច្ច និងការទទួលខុសត្រូវផ្សេងទៀតនៃភាគីណាមួយឡើយ។

## មាត្រា៤០ – សេចក្តីប្រកាស

តាមរយៈសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរជូនចំពោះលោកអគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុប រដ្ឋនីមួយៗអាច (ក្នុងខណៈចុះហត្ថលេខា ឬនៅពេលដែលភាគីដាក់លិខិតូបករណ៍សម្រាប់ធ្វើសច្ចាប័នយល់ព្រម ទទួលយក ឯកភាព ឬចូលជាសមាជិក) ប្រកាសថាខ្លួនមានសមត្ថភាពតម្រូវឲ្យមានចំណុច

មួយ ឬច្រើនបន្ថែមទៀត (ក្នុងករណីចាំបាច់) ដូចមានគ្រោងទុកនៅក្នុងមាត្រា២, ៣, ៦ កថាខណ្ឌទី១.ខ, មាត្រា៧, ៩ កថាខណ្ឌទី៣ និងមាត្រា២៧ កថាខណ្ឌ៩.ង។

## មាត្រា៤១ – ឧសន្យាសហព័ន្ធ

១ រដ្ឋសហព័ន្ធមួយអាចរក្សាសិទ្ធិក្នុងការទទួលយកកាតព្វកិច្ចដែលមាននៅចែងក្នុងជំពូក២ នៃអនុសញ្ញានេះ ក្នុងករណីដែលកាតព្វកិច្ចទាំងនោះត្រូវគ្នានឹងគោលការណ៍ចម្បងដែលកំណត់ទំនាក់ទំនងរវាងរដ្ឋាភិបាលកណ្តាល និងរដ្ឋសមាជិក ឬក៏អង្គភាពដែនដីស្រដៀងគ្នានេះផ្សេងទៀត លុះត្រាតែរដ្ឋនោះអាចសហប្រតិបត្តិការដោយឈរលើមូលដ្ឋាននៃជំពូកទី៣។

២ នៅពេលដែលរដ្ឋសហព័ន្ធមួយធ្វើការបម្រុងទុកនៅកថាខណ្ឌទី១ រដ្ឋនោះមិនអាចប្រើប្រាស់ពាក្យ នៅក្នុងឧបម្រុងបែបនេះ ដើម្បីប្រានចោល ឬកាត់បន្ថយយ៉ាងខ្លាំងក្លានូវកាតព្វកិច្ច ដោយអំណាចនៃជំពូកទី២ ឡើយ។ ទោះបីជាយ៉ាងណា រដ្ឋនោះត្រូវមានមធ្យោបាយច្រើន និងទូលំទូលាយដើម្បីអាចដាក់ឲ្យដំណើរការនូវវិធានការដែលមានគ្រោងទុកដោយជំពូកនោះ។

៣ ចំពោះបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដែលការអនុវត្តស្ថិតនៅក្រោមឱវាទនៃសមត្ថកិច្ចនីតិបញ្ញត្តិនៃរដ្ឋសមាជិកនីមួយៗ ឬអង្គភាពដែនដីដទៃទៀតដែលស្រដៀងគ្នានោះ ហើយដែល (ដោយអំណាចនៃប្រព័ន្ធធម្មនុញ្ញនៃសហព័ន្ធ) មិនអាចចាត់វិធានការនីតិបញ្ញត្តិ រដ្ឋាភិបាលសហព័ន្ធជាមួយនឹងមតិយល់ស្រប ត្រូវផ្តល់ដំណឹងអំពីបទប្បញ្ញត្តិខាងលើនេះជូនទៅអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋសមាជិក ដោយលើកទឹកចិត្តដល់រដ្ឋទាំងនោះឲ្យអនុម័តវិធានការសមស្របដើម្បីដាក់បទប្បញ្ញត្តិទាំងនោះឲ្យដំណើរការ។

## មាត្រា៤២ – ករណីពិសេស

តាមរយៈជូនដំណឹងជាលាយលក្ខណ៍អក្សរជូនចំពោះលោកអគ្គលេខាធិការនៃនៃក្រុមប្រឹក្សាអឺរ៉ុប រដ្ឋនីមួយៗអាច (ក្នុងខណៈចុះហត្ថលេខា ឬដាក់លិខិតូបករណ៍សម្រាប់ធ្វើសច្ចាប័ន យល់ព្រម ទទួលយកឯកភាព ឬចូលជាសមាជិក) ប្រកាសថាខ្លួនកំណត់យកករណីពិសេសមួយ ឬច្រើនដែលមានគ្រោងទុកនៅមាត្រា៤ កថាខណ្ឌទី២, មាត្រា៦ កថាខណ្ឌទី៣, មាត្រា៩ កថាខណ្ឌទី៤, មាត្រា១០ កថាខណ្ឌទី៣, មាត្រា១១ កថាខណ្ឌទី៣, មាត្រា១៤ កថាខណ្ឌទី៣, មាត្រា២២ កថាខណ្ឌទី២, មាត្រា២៩ កថាខណ្ឌទី៤, មាត្រា៤១ កថាខណ្ឌទី១, មាត្រា២២ កថាខណ្ឌទី២។ ករណីពិសេសដទៃទៀត មិនអនុញ្ញាតឲ្យមានឡើយ។

## មាត្រា៤៣ – លក្ខន្តិកៈ និងការលុបចោលករណីពិសេស

១ ភាគីមួយដែលកំណត់ករណីពិសេស ដោយអនុលោមទៅតាមមាត្រា៤២ អាចដកករណីពិសេសទាំងស្រុង ឬមួយផ្នែកវិញ ដោយជូនដំណឹងទៅលោកអគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុប។ ការដកចេញនេះមានសុពលភាពចាប់ពីពេលដែលលោកអគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុបទទួលបានសេចក្តីជូនដំណឹងនោះ។ ថ្វីត្បិតតែបានសេចក្តីជូនដំណឹងបញ្ជាក់ថាការដកករណីពិសេសចាប់មានសុពលភាពនៅក្នុងកាលបរិច្ឆេទមួយជាក់លាក់ តែប្រសិនបើកាលបរិច្ឆេទនោះស្ថិតនៅក្នុងវេលាក្រោយពេលដែលលោកអគ្គ

លេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុបទទួលបានសេចក្ដីជូនដំណឹង ការដកករណីពិសេសនោះចាប់មានសុពលភាពចាប់ពីវេលានោះទៅ។

២ ភាគីមួយដែលកំណត់ករណីពិសេស ដូចបានរៀបរាប់ទៅតាមមាត្រា៤២ អាចដកករណីពិសេសនេះវិញទាំងស្រុង ឬមួយចំណែក បើសិនជាកាលៈទេសៈអនុញ្ញាត។

៣ អគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុបអាចសុំជាទៀងទាត់ឲ្យភាគី ទាំងឡាយដែលបានកំណត់ករណីពិសេសមួយឬច្រើនទៅលើព័ត៌មានស្ដីពីទស្សនវិស័យនៃការដកករណីពិសេស ដូចមានចែងនៅក្នុងមាត្រា៤២។

## មាត្រា៤៤ –វិសោធនកម្ម

១ វិសោធនកម្មទៅលើអនុសញ្ញានេះ អាចត្រូវសំណូមពរឡើងដោយភាគីនីមួយៗ ហើយត្រូវជូនជាដំណឹងដោយអគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុបនៃរដ្ឋសមាជិកនៃក្រុមប្រឹក្សាអឺរ៉ុប ជូនរដ្ឋដែលមិនមែនសមាជិកដែលបានចូលរួមតាក់តែងអនុសញ្ញានេះ ព្រមទាំងជូនដល់រដ្ឋណាដែលបានចូលជាសមាជិក ឬដែលត្រូវបានអញ្ជើញឲ្យចូលជាសមាជិក អនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា៣៧។

២ រាល់វិសោធនកម្មដែលស្នើឡើងដោយភាគីមួយត្រូវបានជូនជាដំណឹងទៅកាន់គណៈកម្មាធិការអឺរ៉ុបប្រឆាំងនឹងបញ្ហាឧក្រិដ្ឋកម្ម (CDPC) ដែលប្រគល់ជូនគណៈកម្មធិការរដ្ឋមន្ត្រីនូវមតិយល់ស្រប ទៅលើវិសោធនកម្មខាងលើនេះ។

៣ គណៈកម្មាធិការរដ្ឋមន្ត្រីនឹងពិនិត្យវិសោធនកម្មដែលស្នើឡើងនោះ និងមតិរបស់ CDPC បន្ទាប់ពីបានពិគ្រោះជាមួយនឹងរដ្ឋមិនមែនសមាជិកនៃអនុសញ្ញានេះ អាចអនុម័តវិសោធនកម្ម។

៤ អត្ថបទនៃវិសោធនកម្មទាំងមូលដែលត្រូវបានអនម័តដោយគណៈកម្មធិការរដ្ឋមន្ត្រី អនុលោមទៅតាមកថាខណ្ឌទី៣នៃមាត្រានេះ ត្រូវជូនជាដំណឹងដល់ភាគីទាំងឡាយដើម្បីឯកភាព។

៥ រាល់វិសោធនកម្មដែលបានអនុម័តដោយអនុលោមទៅតាមកថាខណ្ឌទី៣នៃមាត្រានេះនឹងចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីគ្រប់ភាគីទាំងអស់បានជូនដព័ត៌មានដល់លោកអគ្គលេខាធិការអំពីការឯកភាពរបស់ខ្លួន។

## មាត្រា៤៥ –ការដោះស្រាយទំនាស់

១ គណៈកម្មធិការអឺរ៉ុបប្រឆាំងនឹងបញ្ហាឧក្រិដ្ឋកម្ម នៃក្រុមប្រឹក្សាអឺរ៉ុប (CDPC) ត្រូវទទួលព័ត៌មានអំពីការបកស្រាយ និងការអនុវត្តអនុសញ្ញានេះ។

២ ក្នុងករណីទំនាស់រវាងភាគីទាំងឡាយទៅលើការបកស្រាយ និងការអនុវត្តអនុសញ្ញានេះភាគីទាំងឡាយត្រូវខិតខំដោះស្រាយទំនាស់ តាមរយៈការចរចារ ឬតាមមធ្យោបាយស្ងប់ស្ងាត់ផ្សេងៗទៀតតាមការជ្រើសរើសរបស់ខ្លួន រួមទាំងការប្រគល់ទំនាស់ទៅឲ្យ CDPC ទៅកាន់តុលាការអាជ្ញាកណ្ដាលដែលនឹងទទួលបន្ទុកធ្វើការសម្រេចចិត្តទាក់ទងទៅនឹងទំនាស់នៃភាគី ឬទៅកាន់សាលាក្ដីអន្តរជាតិ ស្របតាមកិច្ចព្រមព្រៀងនៃភាគីពាក់ព័ន្ធ។

## មាត្រា៤៦ – ការពិគ្រោះយោបល់គ្នានៃភាគី

១ ភាគីទាំងឡាយយល់ព្រមព្រៀងគ្នាជាទៀងទាត់ តាមសេចក្តីត្រូវការ ដើម្បីសម្រួលដល់ ៖

ក ការប្រើប្រាស់ និងការដាក់ឲ្យដំណើរការនូវអនុសញ្ញានេះ រួមទាំងការកំណត់អត្តសញ្ញាណនៃរាល់បញ្ហាទាក់ទងនឹងចំណុចនេះ ព្រមទាំងសុពលភាពនៃរាល់សេចក្តីប្រកាស ឬករណីពិសេសដែលត្រូវបានធ្វើឡើងដោយអនុលោមទៅនឹងអនុសញ្ញានេះ។

ខ ការផ្លាស់ប្តូរព័ត៌មានគ្នាស្តីពីបច្ចុប្បន្នភាពថ្មីៗផ្នែកគតិយុត្ត នយោបាយ ឬបច្ចេកទេសសំខាន់ៗដែលត្រូវបានសង្កេតឃើញនៅក្នុងវិស័យឧក្រិដ្ឋកម្មព័ត៌មានវិទ្យា និងការប្រមូលភស្តុតាងប្រើសប្រាស់ប្រព័ន្ធកុំព្យូទ័រ។

គ ការពិនិត្យលទ្ធភាពក្នុងការបំពេញបន្ថែម ឬកែប្រែអនុសញ្ញា។

២ គណៈកម្មាធិការប្រឆាំងនឹងបញ្ហាឧក្រិដ្ឋកម្ម (CDPC) ត្រូវជ្រាបព័ត៌មានជាទៀងទាត់ទាក់ទងទៅនឹងលទ្ធផលនៃការព្រមព្រៀងគ្នាដែលមានចែងនៅក្នុងកថាខណ្ឌទី១។

៣ CDPC ត្រូវសម្រួល តាមសេចក្តីត្រូវការនូវការព្រមព្រៀងគ្នាដូចមានចែងនៅក្នុងកថាខណ្ឌទី១ និងអនុម័តវិធានការចាំបាច់ ដើម្បីជួយដល់ភាគីទាំងឡាយក្នុងការខំប្រឹងប្រែង សំដៅបំពេញបន្ថែម ឬកែប្រែអនុសញ្ញា។ យ៉ាងយូរបំផុតរយៈពេលបីឆ្នាំ គិតពីការចូលជាធរមាននៃអនុសញ្ញានេះទៅ CDPC នឹងធ្វើការពិនិត្យឡើងវិញ ដោយសហប្រតិបត្តិការជាមួយនឹងភាគីទាំងឡាយ ទៅលើបទប្បញ្ញត្តិទាំងអស់នៃអនុសញ្ញា និងសំណូមពរធ្វើវិសោធនកម្មសមស្រប ក្នុងករណីចាំបាច់។

៤ លើកលែងតែក្នុងករណីក្រុមប្រឹក្សាអឺរ៉ុបជាអ្នកទទួលបន្ទុក សោហ៊ុយដែលប្រើប្រាស់តាមឱកាស តាមរយៈការអនុវត្តបទប្បញ្ញត្តិនៃកថាខណ្ឌទី១ ត្រូវឧបត្ថម្ភដោយភាគីទាំងឡាយ ទៅតាមបែបបទដែលភាគីទាំងនោះកំណត់។

៥ ភាគីទាំងឡាយត្រូវទទួលការជួយជ្រោមជ្រែងពីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអឺរ៉ុប ក្នុងការបំពេញមុខងារទៅតាមមាត្រានេះ។

## មាត្រា៤៧ – ការបដិសេធ

១ នៅគ្រប់ខណៈទាំងអស់ ភាគីនីមួយៗអាចបដិសេធអនុសញ្ញានេះ ដោយជូនដំណឹងទៅកាន់អគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុប។

២ ការបដិសេធនឹងមានសុពលភាព នៅថ្ងៃទី១នៃខែដែលបន្តពីខែផុតកំណត់រយៈពេលបីខែ បន្ទាប់ពីលោកអគ្គលេខាធិការទទួលបានសេចក្តីជូនដំណឹង។

## មាត្រា៤៨ – សេចក្តីជូនដំណឹង

អគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុបជូនដំណឹងទៅរដ្ឋសមាជិកនៃក្រុមប្រឹក្សាអឺរ៉ុប ទៅរដ្ឋមិនមែនសមាជិក ដែលបានចូលរួមតាក់តែងអនុសញ្ញានេះ ព្រមទាំងរដ្ឋណាដែលបានចុះឈ្មោះចូលជាសមាជិក ដែលទទួលបានការអញ្ជើញឲ្យចុះឈ្មោះចូលជាសមាជិក អំពី៖

ក រាល់ការចុះហត្ថលេខា

ខ រាល់ការដាក់លិខិតូបករណ៍សម្រាប់ធ្វើសច្ចាប័ន យល់ព្រម ទទួលយក ឯកភាព ឬចូលជាសមាជិក

គ រាល់កាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ អនុលោមទៅតាមមាត្រា៣៦ និង៣៧

ឃ រាល់សេចក្តីប្រកាសដែលធ្វើឡើងដោយអនុវត្តតាមមាត្រា៤០ ឬរាល់ករណីពិសេសទាំងឡាយដែលធ្វើឡើងដោយអនុវត្តតាមមាត្រា៤២

ង រាល់លិខិតដទៃទៀត ការជូនដំណឹង ឬព័ត៌មានដែលទាក់ទងទៅនឹងអនុសញ្ញានេះ។

អាស្រ័យដូចជម្រាបជូនខាងលើ អ្នកមានឈ្មោះក្នុងទីនេះដែលមានសមត្ថកិច្ចស្របច្បាប់ បានចុះហត្ថលេខាលើអនុសញ្ញានេះ។

ធ្វើនៅទីក្រុងប៊ុដាប៉េស្ត ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០១ ជាភាសាបារាំង ភាសាអង់គ្លេស អត្ថបទទាំងពីរច្បាប់សុទ្ធតែមានតម្លៃដូចគ្នា រួមបញ្ចូលគ្នាជា១ច្បាប់ ដែលនឹងត្រូវតម្កល់នៅក្នុងបណ្ណសារនៃក្រុមប្រឹក្សាអឺរ៉ុប។ អគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុបនឹងបញ្ជូនឯកសារថតចម្លងត្រឹមត្រូវតាមច្បាប់ដើមទៅរដ្ឋសមាជិកនីមួយៗនៃក្រុមប្រឹក្សាអឺរ៉ុប ទៅរដ្ឋមិនមែនសមាជិកដែលបានចូលរួមក្នុងការតាក់តែងអនុសញ្ញានេះឡើង និងព្រមទាំងរដ្ឋណាដែលត្រូវបានអញ្ជើញឲ្យមកចុះឈ្មោះចូលជាសមាជិក។